ព្រះសម្ពុទ្ធ ត្រូវព្រហ្មអាកាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្រ ឲ្យប្រព្រឹត្តទៅ ហើយញ៉ាំងមនុស្សនិងទេវតា ចាំងមួយហ្មឺនលោកធាតុ ឲ្យឆ្អែតដោយទឹកអម្រឹត ។ ព្រះលោកនាថអង្គនោះ ទ្រង់មានការត្រាស់ដឹង ៣ លើក គឺ ការត្រាស់ដឹងលើកទី ១ មានពួកសត្វចំនួនមួយសែនកោដិ ។ ការត្រាស់ដឹងលើកទី ២ មានពួកសត្វចំនួនមួយសែនកោដិ ក្នុងកាលដែលព្រះពុទ្ធ ទ្រង់ព្រះនាមអត្ថទស្សី ទ្រង់គ្រាច់ទៅកាន់ទេវាវតៃ ។ តមក ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ចំនួនមួយសែនកោដិ ក្នុងកាលដែលព្រះពុទ្ធជាម្ចាស់ ទ្រង់សម្តែងព្រះធម៌ ក្នុងសំណាក់ព្រះបិតា ។ ព្រះមហេសីអង្គនោះ មានសាវកសន្និបាត (ការជួបជុំសាវ័ក) ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានព្រះទ័យស្ងប់ ប្រកបដោយតាទិគុណ គឺ សន្និបាតលើកទី ១ មានពួកព្រះខីណាស្រព ចំនួន ៩៨ ពាន់អង្គ សន្និបាតលើកទី ២ មានពួកព្រះខីណាស្រព ចំនួន ៩៨ ពាន់អង្គ ។

អដ្ឋសត្តតិសហស្សានំ តតិយោ អាសិ សមាគមោ
អនុចាវិមុត្តានំ វិមលានំ មហេសិនំ ។
អហន្តេន សមយេន ជដិលោ ឧក្កតាបនោ
សុសិមោ ជាម ជាមេន មហិយា សេដ្ឋសម្មតោ ។
និព្ពុំ មញ្ជារុំ បុប្ផំ បទុមំ ចារឯត្តកំ
នេវលោតា អាហរិត្វា សម្ពុទ្ធំ អភិបូជយឺ ។
សោបិ មំ ពុទ្ធោ ព្យាកាសិ អត្ថទស្សី មហាមុនិ
អជ្ជារសេ កប្បសតេ អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បជានំ បធហិត្វាន កត្វា ទុក្ករការកំ ។
អជបាលរុក្ខមូលស្មឺ និសីទិត្វា តថាគតោ
តត្ថ ចាយាសំ បត្តម្ហា នេរញ្ជរមុបេហិតិ ។

សន្និបាតលើកទី ៣ មានពួកព្រះខីណាស្រព ចំនួន ៧៨ ពាន់អង្គ សុទ្ធតែមានព្រះទ័យផុតស្រឡះ ឥតប្រកាន់ ច្រោ-ចាកមន្ទិល ជាអ្នកស្វែងរកគុណដ៏ធំ ។ ក្នុងសម័យនោះ តថាគតកើតជាដដិល ឈ្មោះសុសិម: មានតប.ដ៏ខ្ពង់ខ្ពស់ ដែលគេសន្មតថា ជាបុគ្គលប្រសើរលើផែនដី ។ តថាគត បាននាំយកផ្កាមន្ទារបុស្ប ផ្កាឈូក និងផ្កាចាប៉ាតព្រឹក្ស ជាទិព្វ អំពីទេវលោក មកបូជាចំពោះព្រះសម្ពុទ្ធ ។ ឯព្រះពុទ្ធ ជាមហាមុនី ព្រះនាមអត្ថទស្សីអង្គនោះ ទ្រង់បាន ព្យាករតថាគតថា តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុង កប្បទី ១.៨០០ ។ សត្វនេះ នឹងចេញអំពីបុរី ជាទីរីករាយ ឈ្មោះតបិលពស្តុ តម្កល់ព្យាយាម ហើយធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់ នៃអជបាលព្រឹក្ស ទទួល មធុបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរ ។

បុប្ផសមោ អត្តទស្សីពុទ្ធវំសោ

នេរញ្ជរាយ តីរម្ហិ ទាយាសំ អធិ សោ ជិនោ
បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឋាហិតិ ។
តតោ បឋមេ កាលំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។
ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។
អនាសវា វីតរាគា សន្តចិត្តា សមាហិតា
កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា
អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។
ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថិទារកោ អគ្គោ ហេស្សត្ថុបដ្ឋកោ ។

ព្រះជិនស្រីអគ្គនោះ នឹងសោយមធុបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរ ហើយចូលទៅទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះមានយសធំ នឹងធ្វើប្រទក្សិណាពោធិមណ្ឌៈ ហើយត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះជននីនៃព្រះពោធិសត្វនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ បុរសនេះ នឹងជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងជាអគ្គសាវ័ក ជាអ្នកមិនមានអាសវៈ អស់ពគ: មានចិត្តស្ងប់រម្ងាប់ មានចិត្តតំកល់មាំ កិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអគ្គនេះ ។ ព្រះខេមាថេរី ១ ព្រះឧប្បលវណ្ណាថេរី ១ នឹងជាអគ្គសាវិកា ជាអ្នកមិនមានអាសវៈ អស់ពគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតំកល់មាំ ។ ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអគ្គនោះ ហៅថាអស្សត្ថព្រឹក្ស គហបតីឈ្មោះចិត្ត: ១ គហបតីឈ្មោះហត្ថឡវក: ១ នឹងជាអគ្គឧបដ្ឋាក ។

សុត្តន្តបិដកៃ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

ឧទ្ទមាតា ច ពុទ្ធស្ស អក្កា ហោសុព្ភុបដ្ឋិតា
អាយុ វស្សសតំ តស្ស តោតមស្ស យសស្សិនោ។
ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ
អាមោទិតា នរមរូ ពុទ្ធវីជញ្ជរៃ អយំ ។
ពុក្កដ្ឋិសង្ខា វត្តន្តិ អច្ឆោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ ឧសសហស្សី សទេវតា។
យទិមស្ស ណោកជាថស្ស វិវជ្ជិសុព្ភម សាសនំ
អនាគតម្ហិ អទ្ធានេ ហោសុព្ភម សម្មុខា ឥមំ ។
យថា មនុស្សា ឧទឹ តរន្តា បដិតិត្ថំ វិវជ្ជយ
ហោដ្ឋាតិត្ថំ តហោត្វាន ពុទ្ធវន្តិ មហាឧទឹ ។
ឯវមេវ មយំ សព្ពេ យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ ហោសុព្ភម សម្មុខា ឥមំ ។

នាងនន្ទមាតា ១ នាងឧត្តរា ១ ទាំងជាអគ្គឧបដ្ឋាយិកា ព្រះគោតម មានយសអគ្គនោះ ទ្រង់មានព្រះជន្មាយុ មួយរយឆ្នាំ ។ ពួកមនុស្សនិងទេវតា ឮានស្តាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសី ទ្រង់ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើហើយ ក៏រីករាយថា បុរសនេះ ជាពូជពន្ធុកនៃព្រះពុទ្ធ ។ សម្តេងហ៊ោ ក៏ប្រព្រឹត្តទៅ ពួកមនុស្សព្រមទាំងទេវតា ទាំងមួយហ្មឺនលោកធាតុ នាំគ្នាទះដៃ អបអរ ធ្វើអញ្ជលីនមស្ការថា បើយើងនឹងឃ្លាងមគ្គផល ក្នុងសាសនា នៃព្រះលោកនាថអគ្គនេះ ពួកយើងគង់ទើបានសម្រេច ចំពោះព្រះកក្កុ នៃព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សក្រាលធ្វើនសួន បើឃ្លាងកំពង់ចំពោះមុខហើយ គង់ទឹងទៅកាន់កំពង់ខាងក្រោម ហើយធ្វើសួនធំបាន យ៉ាងណាមិញ ។ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអគ្គនេះ ក៏គង់នឹងបានសម្រេច ចំពោះព្រះកក្កុនៃព្រះគោតមអគ្គនេះ ក្នុងកាលជាអនាគត យ៉ាងនោះដែរ ។

ពុទ្ធសមោ អត្តទស្សីពុទ្ធវំសោ

តស្សាបិ វចនំ សុត្វា តុដ្ឋោ សំវិគ្គមានសោ
ឧត្តរឹ វត្តមដ្ឋាសឹ ឧសភោវមិប្បវិយោ ។
សោភនំ នាម នគរំ សាភវោ នាម ខត្តិយោ
សុទស្សនា នាម ជនិកា អត្តទស្សិសុមហោសិនោ ។
ឆវ វស្សសហស្សានិ អគារំ អជ្ឈាវសិ សោ(១)
អមរតិសុរតិតិវិពាហនា(១) តយោ ចាសុទមុត្តមា ។
តេត្តឹស តិសហស្សានិ នារិយោ សមលង្កតា
វិសាខា នាម សា នារឹ សេលោ នាម អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា អស្សយានេន និក្ខមិ
អនូនអដ្ឋមាសានិ បធានំ បទហឹ ជិនោ ។
ព្រហ្មា យាចិតោ សន្តោ អត្តទស្សឹ មហាយសោ
វត្តចក្កោ មហាវីរោ អនោមទស្សិនេ នមសោ ។

---

១ ឱ. អមរតិវិ សុរតិវិ តិវិពាហនា ។ ម. អមរតិវិសុតិវិពាហនា ។

លុះតថាគត បានស្តាប់ការសិត នៃព្រះលោកនាថអង្គនោះ ហើយ ក៏មានចិត្តត្រេកអរ មានចិត្តតក់ស្លុត ខំអធិដ្ឋានវត្ត តទៅទៀត ដើម្បីបំពេញបារមី ១០ ប្រការ ។ ព្រះមហេសី ព្រះនាមអត្ថទស្សី មានទីក្រុងឈ្មោះសោភណៈ មានព្រះមហាក្សត្រព្រះនាមសាគរ (ជាព្រះបិតា) មានព្រះជននីព្រះនាមសុទស្សនា ។ ព្រះអត្ថទស្សីអង្គនោះ ទ្រង់គ្រងគេហដ្ឋាន អស់ ៩.០០០ ឆ្នាំ មានប្រាសាទប្រសើរ ៣ ខ្នង គឺ ប្រាសាទឈ្មោះអមរគិ ១ ប្រាសាទឈ្មោះ សុរគិ ១ ប្រាសាទឈ្មោះគិរិពោហនៈ ១ ។ នារី ៣៣.០០០ រូប សឹងប្រដាប់យ៉ាងសមសួន ព្រះនារី (ជាអគ្គមហេសី) នោះ ព្រះនាមវិសាខា ព្រះរាជបុត្រ ព្រះនាមសេលៈ ។ ព្រះជនស្រីទ្រង់ឃើញនិមិត្ត ៤ យ៉ាង ហើយទ្រង់ស្តេចចេញទៅដោយយានសេះ តំកល់ព្យាយាម អស់ ៨ ខែគត់ ។ ព្រះអត្ថទស្សីមានយសធំ មានព្យាយាមធំ ទ្រង់ត្រូវព្រហ្មអាពាធនាហើយ ទើបទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងទន្សាយដ៏ថ្លៃថ្លា ។

សន្តោ ច ឧបសន្តោ ច អហោសុំ អក្ខសាវកា

អកាយោ ជាមុបជ្ឈាកោ អត្តទន្តោ មហោសិនោ ។

ឆឡភិ ចេវ សុឆឡភិ ច អហោសុំ អក្ខសាវិកា

ពោធិ តស្សុ កកវតោ ចម្បកោតិ បវុច្ចតិ ។

ឧកុន្ធោ ចេវ និសភោ ច អហោសុំ អគ្គុបដ្ឋកា

មកិលោ ច សុជាតោ ច អហោសុំ អគ្គុបដ្ឋិកា ។

សោបិ ពុទ្ធោ អសមសមោ អសីតិវតនម្ភុតោ

សោភតិ សាលកជាវ ឧទ្ធុភជាវ ប្លវិតោ ។

តស្សុ ចាកកជិកា រំសិ អនេកសតកោដិយោ

ឧទ្ធំ អធោ ទសទិសា ជវន្តិ យោជនំ សតា ។

សោបិ ពុទ្ធោ ឧរុវេលកោ សព្ពសត្តុត្តមោ មុនិ

វស្សសតសហស្សាធិ លោកេ អដ្ឋាសិ ចក្ខុមា ។

ព្រះមហេសី ព្រះនាមអត្តទេវ្យ៏ មានអគ្គសាវ័កពីរអង្គ គឺ ព្រះសន្តៈ ១ ព្រះឧបសន្តៈ ១ មានកិក្ខុជាឧបដ្ឋាក ឈ្មោះ អកយៈ ។ មានព្រះថេរីឈ្មោះធម្មា ១ សុធម្មា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ គេហៅថា ចម្បកព្រឹក្ស ។ ឧបាសកឈ្មោះនកុឡៈ ១ ឈ្មោះទិសកៈ ១ ជាអគ្គឧបដ្ឋាក នាងមកិលា ១ នាងសុនន្ទា ១ ជាអគ្គឧបដ្ឋាយិកា ។ ឯព្រះពុទ្ធអង្គនោះ ទ្រង់ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ មានកំពស់ ៨០ ហត្ថ ទ្រង់រុងរឿងហាក់ដូចដើមសាលរាជព្រឹក្ស ឬដូចព្រះចន្ទ្រពេញវង់ ។ រស្មីជាប្រក្រតី នៃព្រះពុទ្ធអង្គនោះ ប្រែនរយកោដិ តែងផ្សាយទៅកាន់ទិស ទាំង ១០ ទាំងខាងលើ ទាំងខាងក្រោម ចម្ងាយមួយយោជន៍ សព្វ ។ កាល ។ ម្យ៉ាងទៀត ព្រះពុទ្ធអង្គនោះ ប្រសើរជាងជន ខ្ពង់ខ្ពស់ជាងសត្វទាំងពួង ជាអ្នកប្រាជ្ញមានបញ្ញាចក្ខុ បិតនៅក្នុងមនុស្សលោក អស់មួយសែនឆ្នាំ ។

បណ្ណាសមោ ធម្មទស្សីពុទ្ធវំសោ

អតុលំ ឧសេដ្ឋគ្គា ជិកាសំ វិភេទេត្វា សនេវកេ

សោបិ អនិច្ចតំ បត្តោ យថក្កមាធានសន្ធយោ ។

អត្តនស្ស ជិនវរោ អនោមាភមម្ហិ និព្ពុតោ

ជាតុវិត្តារកំ អាសិ តេសុ តេសុ បទេសតោតិ ។

អត្តទស្សីពុទ្ធវំសោ ចុទ្ទសមោ ។

បណ្ណាសមោ ធម្មទស្សីពុទ្ធវំសោ

(๑๖) តស្មេវ មណ្ឌកប្បម្ហិ ធម្មទស្សី មហាយសោ

តមក្ខការំ វិធមិត្វា អតិភេទតិ សនេវកេ ។

តស្សាបិ អតុលតេជស្ស ធម្មចក្កប្បវត្តនេ

កោដិសតសហស្សានំ បឋមាភិសមយោ អហុ ។

ធម្មទស្សិពុទ្ធវង្ស ទី ១៨

ព្រះពុទ្ធនោះ ទ្រង់សម្តែងពន្លឺប្លឹងពុំបាន ញុំាងមនុស្សលោក ព្រមទាំងទេវលោក ឲ្យរុងរឿង ហើយទ្រង់ដល់នូវអនិច្ចតាធម៌ ដូចជាភ្លើងអស់កំញាម ។ ព្រះអត្តទស្សីជិនស្រីដ៏ប្រសើរ ទ្រង់បរិនិព្វាន ក្នុងអនោមាភម មានការសាយភាយទៅនៃព្រះធាតុ ក្នុងប្រទេសទាំងឡាយនោះ ។ ។

ចប់ អត្តទស្សិពុទ្ធវង្ស ទី ១៤ ។

ធម្មទស្សិពុទ្ធវង្ស ទី ១៥

(១៦) ក្នុងមណ្ឌកប្បនោះឯង មានព្រះពុទ្ធ ព្រះនាមធម្មទស្សី មានយសធំ ទ្រង់កំចាត់បង់ងងឹតអន្ធការ ហើយញុំាងមនុស្សលោក ព្រមទាំងទេវលោក ឲ្យរុងរឿង ។ ការត្រាស់ដឹងលើកទី ១ មានពួកសត្វមួយសែនកោដិ ក្នុងការញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ នៃព្រះធម្មទស្សីនោះ ទ្រង់មានតេជះប្លឹងពុំបាន ។

សុត្តន្តបិដកពេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

យតា ពុទ្ធោ ឧម្មទស្សី វិនេសិ សញ្ជយំ ឥសឹ

តតា ឧបតិកោដីនំ ខុតិយាភិសមយោ អហុ។

យតា សរក្ខោ ឧបកញ្ចិ សមវិសោ វិជាយកំ

តតា អសីតិកោដីនំ តតិយាភិសមយោ អហុ។

តស្សាបិ ឧេវឧេវស្ស សន្និចាតា តយោ អាសុំ

ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។

យតា ពុទ្ធោ ឧម្មទស្សី សរណោ វស្សំ ឧចាគមិ

តតា កោដិសហស្សានំ បឋមោ អាសិ សមាគមោ។

បុជាបរំ យតា ពុទ្ធោ ឧេវតោ ឱតិ មាឧសំ

តតាបិ សតកោដីនំ ខុតិយោ អាសិ សមាគមោ។

បុជាបរំ យតា ពុទ្ធោ រកោសេសិ ជុតេ កុណោ

តតា អសីតិកោដីនំ តតិយោ អាសិ សមាគមោ។

ការត្រាស់ដឹងលើកទី ២ មានសត្វចំនួន ៩០ កោដិ ក្នុងកាលដែលព្រះពុទ្ធ ព្រះនាមធម្មទស្សី ទ្រង់ប្បទ្ធានឥសី ឈ្មោះសញ្ជយៈ ។ ការត្រាស់ដឹងលើកទី ៣ មានសត្វចំនួន ៨០ កោដិ ក្នុងកាលដែលសក្កទេវរាជ ព្រមទាំងបរិស័ទ ចូលទៅគាល់ព្រះធម្មទស្សី ទ្រង់ជានាយក ។ ព្រះធម្មទស្សីនោះជាទេវតាក្រៃលែងជាងទេវតា មានសាវកសន្និបាត ៣ លើក សុទ្ធតែជាព្រះខីណាស្រព មានមន្ទិលទៅប្រាសហើយ មានព្រះទ័យស្ងប់ ប្រកបដោយតាទិគុណ ។ សន្និបាតលើកទី ១ មានព្រះខីណាស្រព មួយពាន់កោដិ ក្នុងវេលាដែលព្រះពុទ្ធព្រះនាមធម្មទស្សី ទ្រង់ចូលទៅកាន់វិស្សា ក្នុងអារាម ឈ្មោះសរណៈ ។ សន្និបាតលើកទី ២ មានព្រះខីណាស្រពចំនួន ១០០ កោដិ ក្នុងវេលាដែលព្រះពុទ្ធជាម្ចាស់ ស្តេចចុះចាកទេវលោក មកកាន់មនុស្សលោក ។ មួយទៀត សន្និបាតលើកទី ៣ មានព្រះខីណាស្រព ចំនួន ៨០ កោដិ ក្នុងវេលាដែលព្រះពុទ្ធ ទ្រង់ប្រកាសនូវធុតង្គគុណគាំងឡាយ ។

បណ្ណាសមោ ធម្មទេសនាពុទ្ធវំសោ

អហាន្តេន សមយេន សង្កោ អាសី ពុទ្ធន្តរោ
និព្ពុតន្តេន មាលេន តុវំយេន អភិបូជយឹ ។
សោបិមំ តថា(១)ព្យាការសិ នេវមជ្ឈេ និសីទិយ
អជ្ជាវសកប្បសតេ អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បជានំ បទហិត្វាន កត្វា ទុក្ករការកំ ។
អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ
តត្ថ ចាយាសំ បក្កមេ នេវញ្ជមុបេហិតំ ។
នេវញ្ជកាយ តីវម្ហិ ចាយាសំ អធិ សោ ជនោ
បដិយត្តវរមក្កេន ពោធិមូលម្ហិ ឋហិតំ ។
តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។

---

១ ខ.ម. ពុទ្ធោ ។

ក្នុងសម័យនោះ តថាគតកើតជាព្រះឥន្ទ្រ ឈ្មោះបុរិន្ទទៈ បាន
បូជាព្រះពុទ្ធជាម្ចាស់ ដោយគ្រឿងក្រអូប ផ្កាកម្រង និងតូរ្យតន្ត្រី
ទិព្វ ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់ចំកណ្តាលពួកទេវតា ហើយ
ព្យាករតថាគតថា ក្នុងកប្បទី ១.៨០០ ទៅរាជនេះ នឹងបាន
ត្រាស់ដឹងជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញពីបុរីជាទីគួរត្រេកអរ
ឈ្មោះកបិលពស្តុ ទៅតំកល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វ
នេះ នឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលជ័យយសក្នុងទី
នោះ ហើយចូលទៅឯស្ទឹងនេរញ្ជរ ។ ព្រះពុទ្ធជិនស្រីអង្គនោះ
បានធាន់ជ័យយស ទៀបឆ្នេរស្ទឹងនេរញ្ជរ ហើយនឹងត្រឡប់ទៅ
ឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។
លំដាប់នោះ ព្រះជិនស្រីមានយសធំ នឹងធ្វើប្រទក្សិណពោធិ-
មណ្ឌៈដ៏ប្រសើរ ហើយត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ។

ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ

បិតា សុទ្ធោទនោ នាម អយំ ហោស្សតិ គោតមោ ។

កោលិនោ ឧបតិស្សោ ច អគ្គា ហោស្សន្តិ សាវកា

អនាសវា វីតរាគា សន្តចិត្តា សមាហិតា

អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។

ខេមា ឧប្បលវណ្ណា ច អគ្គា ហោស្សន្តិ សាវិកា

អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។

ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ

ចិត្តោ ច ហត្ថាឡវកោ អគ្គា ហោស្សន្តុបដ្ឋកា ។

ឧត្តរា ច ឧត្តរា អគ្គា ហោស្សន្តុបដ្ឋិកា

អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។

ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ

អាមោទិតា ឥរម្ម ពុទ្ធវីឥង្គ្ហោ អយំ ។

ព្រះជននី នៃព្រះតថាគតនេះ ព្រះនាមមាយាទេវី ព្រះបិតា ព្រះនាមសុទ្ធោទន: ទេវរាជនេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិត: ១ ឧបតិស្ស: ១ នឹងជាអគ្គសាវ័ក ជាអ្នកមិនមានអាសវៈ: មានពគ:អស់ហើយ មានចិត្តស្ងប់រម្ងាប់ មានចិត្តតំកល់មាំ ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ ។ ព្រះខេមាថេរី ១ ព្រះឧប្បលវណ្ណាថេរី ១ នឹងជាអគ្គសាវិកា ជាអ្នកមិនមានអាសវៈ: មានពគ:អស់ហើយ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថាអស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្ត: ១ ឈ្មោះហត្ថាឡវក: ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតាលុះបានស្តាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសី ឥតមានបុគ្គលស្មើ ក៏រីករាយថា ព្រះឥន្ទុនេះ ជាពូជពន្ធុកនៃព្រះពុទ្ធ ។

បណ្ណាវសមោ ធម្មទេសនាពុទ្ធវំសោ

ឧក្កុដ្ឋិសង្ខា វត្តន្តិ អញ្ញោញេន្តិ មាសន្តិ ច
កតញ្ញូបេ ឧមស្សន្តិ ឧសសមាស្ស សនោតា ។
យជិមស្ស លោកជាថស្ស វិវដ្ដិសាម សាសនំ
អជាកតម្ហិ អទ្ធានេ ហោស្សាម សម្មុខា ឥមំ ។
យថា មនុស្សា ឧធិតវន្តា បជិតិតុំ វិវដ្ដិយ
ហោដ្ឋាតិតុំ កហោត្វាន ឧត្តរន្តិ មហាឧធិ ។
ឱវាមេវ មយំ សព្ពេ យធិ មុញ្ចាមិមំ ជិនំ
អជាកតម្ហិ អទ្ធានេ ហោស្សាម សម្មុខា ឥមំ ។
តិស្សាមិ វចនំ សុត្វា កិយ្យោ ចិត្តំ បសាធយិ
ឧត្តរិ វត្តមជិដ្ឋាសិ ឧសចារមិប្បរិយោ ។
សរណំ ជាម ឧកវំ សរណោ ជាម ខត្តិយោ
សុឧក្ខា ជាម ជនិកា ជម្ម ឧទ្ធសរិស្ស សត្តជោ ។

សម្ដេចហ្នឹង កំប្រព្រឹត្តទៅ ពួកមនុស្សព្រមទាំងទេវតា ទាំង
មួយហ្នឹងលោកធាតុ នាំគ្នាទៅដែរអបអរ ធ្វើអញ្ជលីនមស្ការថា
បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនា នៃព្រះលោកនាថ
អង្គនេះ ពួកយើងគង់ទទឹងបានសម្រេច ចំពោះព្រះកត្តិនៃព្រះ
គោតមនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្ស កាល
ទឹងធ្វងស្ងឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាង
ក្រោម ហើយធ្វងស្ងឹងធំបាន យ៉ាងណាមិញ ។ ពួកយើង
ទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះ គង់ទឹងបានសម្រេច
ចំពោះព្រះកត្តិ នៃព្រះគោតម ក្នុងកាលជាអនាគតមិនខាន
យ៉ាងនោះឯង ។ តថាគត លុះបានស្តាប់កាសិតនៃព្រះជិនស្រី
អង្គនោះហើយ កំញាំងចិត្តឲ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋាន
វត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ។ ព្រះសាស្តាព្រះ
នាមជម្ពុទស្សី មានទីក្រុងឈ្មោះសរណៈ មានមហាក្សត្រព្រះ
នាមសរណៈ ជាព្រះបិតា មានព្រះជននី ព្រះនាមសុនន្ទា ។

สุตฺตนฺตปิฏกេ ขុទ្ទកនិកាយស្ស ពុទ្ធវំសោ

អដ្ឋវស្សសហាបញ្ចនិ អតារំ អដ្ឋារសិ សោ
អរញ្ញោ វិវរញ្ញោ សុទស្សញ្ញោ តយោ ចាសាធមុត្តមោ ។
ចត្តាឌ្ឍឡីស សហាស្សានិ ជារិយោ សមលង្កតា
វិចិត្តោលី ជាម ជារី អត្រញ្ញោ បុញ្ញវន្តរោ ។
ឯមិត្តេ ចតុរោ និស្សា ចាសាធេជាភិនិក្ខមិ
សត្តាហំ បជាធចារំ អចរិ បុរិសុត្តមោ ។
ព្រហ្មាជា យាចិតោ សន្តោ ធម្មទស្សី ឧភាសភោ
វត្តចក្កោ មហាវីរោ មិគជាយេ ឧវត្តមោ ។
បទុមោ បុស្សនេរោ ច អរោសុំ អគ្គសាវកា
សុទត្តោ(๑) ជាមុបដ្ឋាកោ ធម្មទស្សិស្ស សត្ថុនោ ។
ខេមា ច សក្ខជាមា ច អរោសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ តិម្ពរុជាលោតិ(๒) វុច្ចតិ ។

---

๑ ឧ. ម. សុនេត្តោ ។ ๒ ឧ. ពិម្ពរុជាលោតិ ។ ម. ពិម្ពិជាលោតិ ។

ព្រះធម្មទស្សីអគ្គនោះ ទ្រង់គ្រប់គ្រងគេហស្ថាន អស់ ៨ ពាន់ឆ្នាំ ទ្រង់មានប្រាសាទ ៣ ខ្នង គឺប្រាសាទឈ្មោះអរជៈ ១ ប្រាសាទឈ្មោះវរជៈ ១ ប្រាសាទឈ្មោះសុទស្សនៈ ១ ។ ពួកនារីចំនួន ៤០ ពាន់ សឹងប្រដាប់ខ្នងយ៉ាងសមស្ងួន នារី (ជាអគ្គមហេសី) ឈ្មោះវិចិកោលី ព្រះរាជបុត្រ ឈ្មោះបុញ្ញវឌ្ឍនៈ ។ ព្រះធម្មទស្សី ជាបុរសដ៏ប្រសើរ ទ្រង់ឃើញនូវនិមិត្ត ៤ ហើយទ្រង់ចេញទៅកាន់ប្រាសាទ ទៅប្រព្រឹត្តព្យាយាម អស់ ៧ ថ្ងៃ ។ ព្រះពុទ្ធព្រះនាមធម្មទស្សី ប្រសើរជាងពួកជន មានព្យាយាមធំ ឧត្តមជាងជន ត្រូវព្រហ្មអាពាធនាហើយ ទើបទ្រង់ញុំាងធម្មចក្រ ឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ។ ព្រះសាស្តា ព្រះនាមធម្មទស្សី មានព្រះបទុមត្ថេរ ១ ព្រះបុស្សទេវត្ថេរ ១ ជាអគ្គសាវ័ក ព្រះសុទត្តត្ថេរ ជាឧបដ្ឋាក ។ មានព្រះខេមាថេរី ១ ព្រះសច្ចនាមាថេរី ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ គេហៅថា តិម្ពជាលព្រឹក្ស ។

បណ្ណាសមោ ធម្មទេសនាពុទ្ធវំសោ

សុភន្ធោ ភគវាសព្ពហោ ជេវ អហោសុំ អក្ខុបដ្ឋភា

សាធ្បិសា(๑) ច ភទ្ធិសព្ភ(๒) ច អហោសុំ អក្ខុបដ្ឋភា។

សោបិ ពុទ្ធោ អសមសមោ អសីតិមហាតម្ភុក្ខតោ

អតិភោចតិ តេជេន ទសសហស្សម្ហិ ជាតុយា។

សុជ្ជុល្ហោ សាលរាជាវ វិជ្ជុ ភគវេ យថា

មជ្ឈន្តិកោវ សុរិយោ ឱវំ សោ ឧបសោភថ។

តស្សាបិ អតុលតេជស្ស សមភំ អាសិ ជីវិតំ

វស្សសតសហស្សានិ លោកេ អដ្ឋាសិ ចក្ខុមា។

ទុភាសំ ទស្សយិត្វាន វិមលំ ភត្វាន សាសនំ

ចរិ(៣) ចន្តោវ ភគវេ ឯពុតោ សោ សសារកោតិ។

---

๑ ឧ. ម. សាឍ្ឍិយា ។ ๒ ឧ. រិដ្ឋិយា ។ ម. ភទ្ធិយា ។ ๓ ឧ. រិរោបយិ ។ ។ ម. រិ ។

ធម្មទេសិតាពុទ្ធវង្ស ទី ๑๔

សុភទ្ធគហបតី๑ កដិស្សហគហបតី๑ ជាអគ្គឧបដ្ឋាក នាង
សាឡិសា ๑ នាងភទ្ទិស្សា ๑ ជាអគ្គឧបដ្ឋាយិកា ។ ព្រះពុទ្ធ
នោះ ទ្រង់ស្នេហាយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ទ្រង់
មានកំពស់ ๘๐ ហត្ថ ទ្រង់រុងរឿងក្រៃលែង ដោយតេជះ
ក្នុងមួយហ្មឺនលោកធាតុ ។ ដើមសាលរាជព្រឹក្ស មានផ្កា
រីកស្គុះស្គាយល្អ ផ្លែកបន្លោរលើអាកាស ព្រះអាទិត្យនាថ្ងៃ
ត្រង់ រុងរឿងល្អ យ៉ាងណាមិញ ព្រះពុទ្ធអង្គនោះ ទ្រង់
រុងរឿងល្អ យ៉ាងនោះ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានតេជះ
ថ្លឹងពុំបាន មានជីវិតដ៏ស្មើល្អ ព្រះពុទ្ធមានបញ្ចាចក្ខុ ទ្រង់បិត
នៅក្នុងលោក អស់មួយសែនឆ្នាំ ។ ព្រះពុទ្ធអង្គនោះ ព្រម
ទាំងសាវ័ក ទ្រង់សម្តែងវស្សី ធ្វើសាសនាមិនឲ្យមានមន្ទិល
ដូចព្រះចន្ទ្រ កាលរុងរឿងឰដ៏អាកាស ហើយបរិនិព្វាន ។

สุตฺตนฺตปิฏกេ ขុទ្ទកនិកាយស្ស ពុទ្ធវំសេ

ឆម្ភទនស្ស មហារីរេ កោសាវមម្ហិ(๑) និព្ពុតោ
តស្សេវ សោ ភូបវរេ តីណិ យោជនបុត្ថតោតិ ។

ធម្មទស្សិពុទ្ធវំសោ បណ្ណរសមោ ។

សោឡសមោ សិទ្ធត្ថពុទ្ធវំសោ

[๑๗] ឆម្ភទនស្សានុជស្ស អបរេន សិទ្ធត្ថោ លោកនាយកោ
និហន្ត្វាន តមំ សព្ពំ សុរិយោ អព្ភុគ្គតោ យថា ។
សោបិ បត្វាន សម្ពោធិំ សព្ពារេឡោ សនេវកំ
អតិវស្សំ ធម្មមេឃេន និព្ពាបេត្វោ សនេវកំ ។
តស្សាបិ អតុលតេជស្ស អហោសុំ អតិសមយា តយោ
កោដិសតសហស្សានំ បឋមាភិសមយេ អហុ ។

๑ ម. សាលវាម្ហិ ។

ព្រះធម្មទស្សី ទ្រង់មានពាយាមធំ ទ្រង់បរិនិព្វានក្នុងអារាម
ឈ្មោះកេសៈ ព្រះស្តូបដ៏ប្រសើរនោះ របស់ព្រះពុទ្ធអគ្គ
នោះឯង មានកំពស់ ៣ យ៉ោជន៍ ។

ចប់ ធម្មទស្សីពុទ្ធវង្ស ទី ១៥ ។

សិទ្ធត្ថពុទ្ធវង្ស ទី ១៦

(១៧) ក្រោយអំពីព្រះធម្មទស្សីមក មានព្រះលោកនាយក
ព្រះនាមសិទ្ធត្ថៈ ទ្រង់កំចាត់បង់ងងឹតទាំងអស់ បីដូចព្រះ
អាទិត្យរះឡើង ។ ព្រះសិទ្ធត្ថៈអង្គនោះ ទ្រង់ដល់នូវសម្ពោ-
ធិញ្ញាណ ហើយចម្រើនមនុស្សព្រមទាំងទេវតា បង្អុរភ្លៀងគឺ
ធម៌ ហើយញុំាងមនុស្ស ព្រមទាំងទេវតា ឲ្យរលត់ទុក្ខ ។
ព្រះអង្គមានតេជៈថ្លឹងពុំបាន ទ្រង់មានការត្រាស់ដឹង ៣ លើក
គឺ ការត្រាស់ដឹងលើកទី ១ មានពួកសត្វមួយសែនកោដិ ។

សោឡសមោ សិទ្ធត្ថពុទ្ធវំសោ

បុរាបរំ ភគវតោ យថា[1] អាហារំ ឧទ្ធរី[2]
តទា ឧបវុត្ថកោដីនំ ខុត្តិយោភិសមយោ អហុ ។
យទា ពុទ្ធោ ឆម្ភិ នេសេសិ វេភារេ សោ ឧបវត្តមោ
តទា ឧបវុត្ថកោដីនំ តតិយោភិសមយោ អហុ ។
សន្និចាតា តយោ អាសុំ សិទ្ធិត្ថស្ស មហេសិនោ[3]
ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។
កោដិសតានំ ឧបវុត្ថា អសីតិយា ច កោដិនំ
ឯតេ អាសុំ តយោ ហោន្តា វិមលានំ សមាគមេ ។
អហាន្តេន សមយេន មច្ឆរិយោ ជាម តាបសោ
ខគ្គតេជោ ឧបច្ឆសហោ អភិញ្ញាពលសមាហិតោ ។
ជម្ពុតោ ឆលភិញ្ញាហិ សិទ្ធត្ថស្ស អធាសហំ
បដិក្កហេត្វាន សម្ពុទ្ធោ ឥធំ វចនមព្រវិ ។

---

๑ ឱ. យទិ ។ ម. យថា ។ ๒ ឱ. ខុប្រភំ ។ ๓ ឱ. ម. តស្មិំបិ ទីបទុត្តមេតិ ទិស្សតិ ។ ម. តស្សាបិ ទ្វិបទុត្តមេ ។

សិទ្ធត្ថពុទ្ធវង្ស ទី ១៦

តមក ការត្រាស់ដឹងលើកទី ២ មានពួកសត្វ ៩០ កោដិ ក្នុងកាលព្រះសម្ពុទ្ធ ទ្រង់ទូន្មានគឺធម៌ ក្នុងដែនឈ្មោះកីមៈ ។ ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៩០ កោដិ ក្នុងកាលដែលព្រះពុទ្ធប្រសើរជាងជនអង្គនោះ ទ្រង់សម្តែងធម៌ ទៀបក្នុងឈ្មោះវេការៈ ។ ព្រះមហេសី ព្រះនាមសិទ្ធត្ថៈ មានសន្និបាត ៣ លើក សុទ្ធតែព្រះខីណាស្រព ឥតមានមន្ទិល មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ ឋានៈគឺសន្និបាតទាំង ៣ ក្នុងសមាគមនៃព្រះខីណាស្រព ដែលមិនមានមន្ទិលនុ៎ះ មានចំនួន ១០០ កោដិម្ភង ៩០ កោដិម្ភង ៨០ កោដិម្ភង ។ សម័យនោះ តថាគតជាតាបស ឈ្មោះមង្គលៈ មានតេជះខ្ពង់ខ្ពស់ គេគ្របសង្កត់មិនបាន ជាអ្នកប្រកបដោយកម្លាំង នៃអភិញ្ញា ។ តថាគតបាននាំផ្លែព្រីងមកថ្វាយព្រះពុទ្ធ ព្រះនាមសិទ្ធត្ថៈ ព្រះសម្ពុទ្ធទ្រង់ទទួលយកហើយ ទ្រង់បានត្រាស់ព្រះតម្រាស់នេះថា

สุត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

បស្សថ ឥមំ តាបសំ ជដិលំ ឧក្កតាបនំ

ចតុន្នវុតេ ឥតោ កប្បេ អយំ ពុទ្ធោ កវិស្សតិ ។

អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ

បធានំ បធហិត្វាន កត្វា ទុក្ករការិកំ ។

អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ

តត្ត ចាយាសំ បក្ខន្ទោ នេរញ្ជរមុបេហិតិ ។

នេរញ្ជរាយ តីរម្ហិ ចាយាសំ អទិ សោ ជិនោ

បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឋហិតិ ។

តតោ បធក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ

អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។

ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ

បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។

អ្នកចាំដណ្ឌាយ ចូរមើលជដិលតាបស ដែលមានតបៈខ្ពង់-
ខ្ពស់នេះចុះ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុង
កប្បទី ៩៤ អំពីកប្បនេះទៅ ។ សត្វនេះ នឹងចេញពីបុរី
ឈ្មោះកបិលពស្តុ ជាទីកកាយ ទៅតំកល់ព្យាយាម ធ្វើ
ទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស
ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរ ។
ព្រះជិនស្រីអង្គនោះ បាននាំយកបាយាស ទៀបឆ្នេរស្ទឹង
នេរញ្ជរ ហើយស្តេចត្រឡប់ចូលទៅឯគល់ពោធិព្រឹក្ស តាម
ផ្លូវប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះ
ជិនស្រី ទ្រង់មានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ
ហើយនឹងត្រាស់ដឹង ទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះជនទី
នៃព្រះគោតមនេះ ព្រះនាមមាយា ព្រះបិតា ព្រះនាមសុ-
ទ្ធោទនៈ តាបសនេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។

សោឡសមោ សិទ្ធត្តពុទ្ធវំសោ

កោលិតោ ឧបតិស្សោ ច អគ្គា ភោសុទ្ធិ សាវកា
អជាសកា វីតភតា សន្តចិត្តា សមាហិតា
អានន្ទោ ជាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណោ ច អគ្គា ភោសុទ្ធិ សាវិកា
អជាសកា វីតភតា សន្តចិត្តា សមាហិតា ។
ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ អគ្គា ភោសុទ្ធុបដ្ឋកា ។
ឧត្តរា តា ច ឧត្តរ អគ្គា ភោសុទ្ធុបដ្ឋិកា
អាយុ វស្សសតំ តស្ស តោតមស្ស យសស្សិនោ ។
ឥទំ សុត្វាន វចនំ អសមស្ស មហោសិនោ
អាមោទិតា នរមរូ ពុទ្ធវីជញ្ជរេ អយំ ។

សិទ្ធត្តពុទ្ធវង្ស ទី ១៦

ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ ទី៨ជាអគ្គសាវ័ក សុទ្ធតែមិនមានអាសវៈ មានពគៈអស់ហើយ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ កិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ ទី៨បម្រើព្រះជិនស្រីអង្គនេះ ។ ខេមាថេរី ១ ឧប្បលវណ្ណាថេរី ១ ទី៨ជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ មានពគៈអស់ហើយ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើជាទីត្រាស់ដឹងនៃព្រះមានជាគនោះ ហៅថា អស្សត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ ទី៨ជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ ជាអគ្គឧបដ្ឋាយិកា ព្រះគោតមទ្រង់យសអង្គនោះ មានព្រះជន្មាយុ មួយរយឆ្នាំ ។ មនុស្សទាំងទេវតាបានស្តាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសី ឥតមានបុគ្គលស្មើ ក៏រីករាយថា តាបសនេះ ជាពួជពន្ធុកនៃព្រះពុទ្ធ ។

ទុក្ករំ ទីឃសង្ខា វត្តន្តិ អច្ឆោដេន្តិ ហាសន្តិ ច
តតញ្ចលី ឧមស្សន្តិ ឧសសហស្សំ សនេវកា ។
យទិមស្ស លោកជាឋស្ស វិវដ្ដិស្សាម សាសនំ
អជាកតម្ហិ អទ្ធានេ ហោស្សាម សម្មុខា ឥមំ ។
យថា មនុស្សា ឧទឹតវត្តា បដិតន្តំ វិវដ្ដិយ
ហោដ្ឋាតិតុំ កហោត្វាន ទុត្តរន្តិ មហាឧទឹ ។
ឯវមេវ មយំ សព្ពេ យទិ មុញ្ចាមិមំ ជិនំ
អជាកតម្ហិ អទ្ធានេ ហោស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា កាយ្យា ចិត្តំ បសាទយឹ
ទុត្តរំ វត្តមដ្ឋាសឹ ឧសចារមិវូរយា ។
វេភារំ ជាម ឧភរំ ទុនេដោ ជាម ទក្ខិណេយ្យោ
សុជស្សុ ជាម ឧដិកា សិទ្ធត្ថស្ស មហោសធោ ។

សម្ដែងហ៊ោកប្រព្រឹត្តទៅ ពួកមនុស្សព្រមទាំងទេវតា ទាំង
មួយហ្មឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា
បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថ
អង្គនេះ ពួកយើងគង់នឹងបានសម្រេច ចំពោះព្រះភក្ត្រនៃ
ព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្ស
កាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់ទៅកាន់កំពង់
ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណា ។ ពួកយើង
ទាំងអស់ បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេច
ចំពោះព្រះភក្ត្រព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន
យ៉ាងនោះដែរ ។ តថាគត លុះស្តាប់ការសិតនៃព្រះពុទ្ធ ព្រះ
នាមសិទ្ធត្ថៈនោះហើយ ក៏ធ្វើចិត្តឱ្យជ្រះថ្លាក្រៃលែង បាន
អធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ។ ព្រះមហោសី
ព្រះនាមសិទ្ធត្ថៈ មានទីក្រុងឈ្មោះវេការៈ ព្រះមហាក្សត្រ
ព្រះនាមទេនៈ ជាព្រះបិតា ព្រះជននីព្រះនាមសុផស្សា ។

សោឡសមោ សិទ្ធត្ថពុទ្ធវំសោ

ឥស វស្សសហស្សានិ អការំ អជ្ឈាវសិ សោ

តោ តាសុបវ្ជ្ជលតោ តកឌ្ឍនា តយោ ថាសាឥមុត្តមា ។

តិសោឡ្ឍសសហស្សានិ ជាវិយោ សមលង្កតា

សុមជា ជាម សា ជាវី អឌ្ឍមោ ជាម អត្រជោ ។

ឯមិត្តេ ឆត្តរោ ឥស្សា សិវិតោ យោភិនិក្ខមិ

អឌ្ឍនឥសមាសានិ បជានំ បឥហី ជិនោ ។

ព្រហ្មា ជា យាចិតោ សន្តោ សិទ្ធត្តោ លោកនាយកោ

វត្តចក្កោ មហាវីរោ មិតនាយេ ឧវត្តមោ ។

សម្ពលោ ច សុមិត្តោ ច អហោសុំ អគ្គសាវកោ

រេវតោ ជាមុបដ្ឋាកោ សិទ្ធត្តស្ស មហេសិនោ ។

សីវលោ ច សុភទ្ទា ច អហោសុំ អគ្គសាវិកោ

ពោធិ តស្ស ភគវតោ កណ្ណិកោរោតិ វុច្ចតិ ។

ព្រះសិទ្ធត្ថៈនោះ គ្រប់គ្រងគេហដ្ឋាន អស់មួយហ្មឺនឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺកោកាសប្រាសាទ ១ ឧប្បលប្រាសាទ ១ កោកនុទប្រាសាទ ១ ។ នារី ៤៨.០០០រូប សឹងមានខ្លួនតាក់តែងល្អ នារីជាអគ្គមហេសី ព្រះនាមសុមនា មានព្រះរាជបុត្រ ព្រះនាមអនុបមៈ ។ ព្រះជនស្រីទ្រង់ឃើញនិមិត្ត ៤ យ៉ាង ក៏ចេញទៅដោយរថ តម្កល់ព្យាយាម អស់ ១០ ខែគត់ ។ ព្រះលោកនាយក ព្រះនាមសិទ្ធត្ថៈ មានព្យាយាមធំ ប្រសើរជាងជន ត្រូវព្រហ្មអារាធនាហើយ ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ។ ព្រះមហេសី ព្រះនាមសិទ្ធត្ថៈ មានព្រះសម្ពលត្ថេរ ១ ព្រះសុមិត្តត្ថេរ ១ ជាអគ្គសាវ័ក កិក្ខុឈ្មោះរេវតៈ ជាឧបដ្ឋាក ។ ព្រះសីវលាថេរី ១ ព្រះសុរាមាថេរី ១ ជាអគ្គសាវិកា ដើមឈើជាទីត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថាកណ្ណិការព្រឹក្ស ។

สุตฺตนฺตปิฏเก ขุทฺทกนิกายเย สุตฺต พุทฺธวํเส

สุปฺปิโย จ สมฺพุทฺโธ จ อเหสุ์ อคฺคุปฏฺฐกา
ทฺเว เจว สุทฺธา จ อเหสุ์ อคฺคุปฏฺฐิกา ฯ
เสา พุทฺโธ สฏฺฐิกปฺเปน(๑) อเหกสิ ภิกฺขุสงฺฆโต
กญฺจนกฺขนฺธสงฺกาเสา ทสสหสฺสี วิโรจติ ฯ
เสาปิ พุทฺโธ อสมสมา อสุโล อปฺปฏิปุคฺคโล
วสฺสสตสหสฺสานิ โลเก อฏฺฐาสิ ธมฺมา ฯ
วิปุลปฺปกาสิ ทสฺสยิตฺวา ปุจฺฉาเยตฺวาน สาวเก
วิลาเสตฺวา วสมาปตฺติยา นิพฺพุโต เสา สสาวเกา ฯ
สิทฺธตฺถา มุนิวโร พุทฺโธ อโนมาคมฺหิ นิพฺพุโต
ตสฺส ตสฺส ถูปวโร จตุยาชนมุคฺคโตติ ฯ

สิทฺธตฺถพุทฺธวํเส เสฬสมา ฯ

---

๑ สิทฺธิรตฺถาติ ยุตฺตมิว ฯ

សុប្បិយគហបតី ១ សម្ពុទ្ធគហបតី ១ ជាអ្នកបម្រើដ៏ប្រសើរ រម្ភទុបាសិកា ១ សុរម្ភទុបាសិកា ១ ជាស្រីបម្រើប្រសើរ ។ ព្រះពុទ្ធអគ្គនោះ ទ្រង់មានកំពស់ ៦០ ហត្ថ ទ្រង់ខ្ពស់ដល់អាកាស ប្រាកដស្មើដោយគ្រឿងបូជាមាស ទ្រង់រុងរឿងអស់មួយហ្មឺនលោកធាតុ ។ ព្រះពុទ្ធអគ្គនោះ ទ្រង់ស្មើដោយព្រះពុទ្ធដែលមិនមានបុគ្គលស្មើ ឥតមានបុគ្គលប្លែងបាន ឥតមានបុគ្គលប្រៀបផ្ទឹមបាន ទ្រង់មានបក្ខ បិតនៅក្នុងលោកអស់មួយសែនឆ្នាំ ។ ព្រះពុទ្ធអគ្គនោះ ព្រមទាំងសាវ័ក ទ្រង់សម្តែងពន្ធឹក្តីត្រចះ ហើយញុំាងសាវ័ក ឲ្យសាយកាយ៧ ទ្រង់ក្រសាលដោយសមាបត្តិដ៏ប្រសើរ ហើយបរិនិព្វាន ។ ព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ ជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងអនោមាភម ព្រះស្តូបដ៏ប្រសើរ នៃព្រះអង្គនោះ មានកំពស់ ៤ យោជន៍ ប្រតិស្ឋាននៅ ក្នុងអនោមាភមនោះឯង ។

ចប់ សិទ្ធត្ថពុទ្ធវង្ស ទី ១៦ ។

สาตฺถสเมา ตติยพุทฺธวีสเมา

(๑๘) สิทฺธตฺถสฺส อปเรน อสเมา อปฺปฏิปุคฺคลเมา
อนนฺตสีลเมา(๑) อมิตยเสา ตสฺสาปิ โลกคฺค-
นายกสฺส ฯ

ตมนฺธการํ วิธมิตฺวา ชิตาเสตฺวา สเตหกึ
อนุกมฺปโก มหาวีโร โลเก อุปฺปชฺชิ จกฺขุมา ฯ
ตสฺสาปิ อตุลา ฉนฺทิ อตุลา สีลสมาธิโย
สพฺพตฺถ จาปิ ตาทิตฺตา ธมฺมจกฺกึ ปวตฺตยิ ฯ
โส ภุญฺชิ ธนสมฺปนฺนึ วิญฺญาปยิ ตโย ปุถี
โกฏิสตานิ อกิลมนฺโต ปปาเย ธมฺมเทสนาย ฯ
ขุตฺตโย ธาตุโกฏีนึ ตตฺถ สฏฺฐิโกฏิโย
พฺยากา โส ปโมเจสิ สมฺปตฺเต ธมฺมทสฺสเน ฯ

๑ ม. อนนฺตเตชเมา ฯ

តិស្សពុទ្ធវង្ស ទី ๑๓

(๑๘) ក្រោយពីព្រះពុទ្ធ ព្រះនាមសិទ្ធត្ថៈមក មានព្រះពុទ្ធ ព្រះនាមតិស្សៈ ជានាយកដ៏ប្រសើរ ក្នុងលោក ទ្រង់មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹមបាន មានសីលរកទីបំផុតគ្មាន មានយសរាប់ពុំបាន ទ្រង់មានសេចក្តីអាណិតអាសូរ មានព្យាយាមធំ មានបក្ខ ទ្រង់កើតឡើងក្នុងលោកកំចាត់បង់ធំដ៏តអន្ធការ ញ៉ាំងលោកនេះ ព្រមទាំងទេវលោកឲ្យភ្លឺស្វាងហើយ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានឫទ្ធិថ្លឹងពុំបាន មានសីលសមាធិថ្លឹងពុំបាន ព្រះអង្គសម្រេចទៅបារមី ក្នុងធម៌ទាំងពួង ហើយទ្រង់ញ៉ាំងចក្រគឺធម៌ ឲ្យប្រព្រឹត្តទៅ ។ ព្រះពុទ្ធនោះ ទ្រង់បញ្ចេញព្រះសូរសៀងដ៏ជ្រះស្អាតល្អ ក្នុងលោកធាតុមួយហ្មឺន ពួកសត្វទាំងមួយរយកោដិ សឹងបានត្រាស់ដឹង ក្នុងការសម្តែងធម៌លើកទី ๑ ។ ការត្រាស់ដឹងលើកទី ๒ មានពួកសត្វ ๙๐ កោដិ ការត្រាស់ដឹងលើកទី ๓ មានពួកសត្វ ๖๐ កោដិ ពេលនោះ ព្រះសម្ពុទ្ធនោះទ្រង់ដោះមនុស្សទេវតា ដែលមកដល់ឲ្យរួចចាកចំណងគឺមារ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

សង្ខ្ចាតា តយោ អាសុំ តិស្សុស្សុ ច មហេសិនោ(๑)
ខីណាសវានំ វិមលានំ សព្ពចិត្តាន តាទិនំ ។

ខីណាសវសតសហស្សានំ បឋមោ អាសិ សមាគមោ
ឯកូតិសតសហស្សានំ ទុតិយោ អាសិ សមាគមោ ។
អសីតិសតសហស្សានំ តតិយោ អាសិ សមាគមោ
ខីណាសវានំ វិមលានំ បុប្ផិតានំ វិមុត្តិយា ។

អហាន្តេន សមយេន សុជាតោ នាម ខត្តិយោ
មហាភោគំ ឆឌ្ឌយិត្វា បព្ភជឺ ឥសិបព្ភជ្ជំ ។

មយិ បព្ភជិតេ សន្តេ ឧបច្ឆដ្ឋិ លោកនាយកោ
ពុទ្ធោតិ សទ្ទំ សុត្វាន បីតិ មេ ឧបបជ្ជថ ។

ឥតិពុទ្ធោ មង្គលវំ បុប្ផិំ បទុមំ ហារំឆត្តកំ
ឧភោ ហត្ថេហិ បគ្គយ្ហ ឆុឧមាយោ ឧហាតមិំ ។

---

๑ ឧ. ម. តិស្សោ លោកគ្គនាយកោតិ ទិស្សន្តិ ។

ព្រះតិស្សមេហេសី មានសាវកសន្និបាត ៣ លើក ដែល
សុទ្ធសឹងតែជាពួកព្រះខីណាស្រព មិនមានមន្ទិលគឺកិលេស
មានចិត្តស្ងប់រម្ងាប់ ប្រកបដោយគាទិគុណ ។ សន្និបាត
លើកទី ១ មានព្រះខីណាស្រពមួយសែនអគ្គ សន្និបាតលើក
ទី ២ មានព្រះខីណាស្រព ៩០ សែនអគ្គ ។ សន្និបាតលើក
ទី ៣ មានព្រះខីណាស្រព ៨០ សែនអគ្គ សុទ្ធតែជាអ្នកអស់
អាសវៈ ឥតមានមន្ទិលគឺកិលេស រកហើយដោយរម្ងុត្តិ ។
គ្រានោះ តថាគតជាក្សត្រនាមសុជាតៈ លះបង់លោគៈ
ដ៏ច្រើន ហើយទៅបួសជាឥសី ។ កាលដែលតថាគត បួស
ស្រេចហើយ ព្រះលោកនាយកទ្រង់កើតឡើង តថាគតកើត
មានបីតិ ព្រោះបានស្តាប់សម្លេងជាព្រះពុទ្ធ ។ តថាគតបាន
កាន់យកផ្កាមន្ទារព្រឹក្ស ផ្កាឈូក និងផ្កាចំបកព្រឹក្ស ជា
ទិព្វ ដោយដៃទាំងពីរ ដង្ហុះរលាស់ ហើយបូជាទៅតាល់ ។

สตฺตาสเมา ติสฺสพุทฺธวีสเมา

ชาตุวณฺณา ปวรุตฺตมา(๑)　　ตีสุปิ โลเก กตฺตายกา
ตมหา ปุญฺญา ตเมาตฺตา　　มตฺตเก ชาเย ชินา ๆ
เสาปิ มาตา(๒) ปฺรากาสิ　　ชนมาเฒฺย ธิสีธิเย
ทฺวาทสุเต ฯเตา กเปฺป　　อยิ พุทฺธา กวีสุตี ๆ
อหา กปิลปุเรา รมฺมา　　ธิกฺขิตฺตา ตถาคเตา
ปฐมา ปธิมาตฺตาน　　กตฺวา ทุกฺกรการกา ๆ
อชชาลรุกฺขมูลสฺมี　　ธิสีธิตฺวา ตถาคเตา
ตตฺถ ชายาสา ปกฺขยา　　เนรญฺชรมุเปหิตา ๆ
เนรญฺชกาย ตีรมฺหิ　　ชายาสา อธิเสา ชิเนา
ปฐิยตฺถรมกฺเขน　　เพาธิมูลมฺหิ เวหิตา ๆ
ตเตา ปธกฺขิณา กตฺวา　　เพาธิมณฺฑา อทุตฺตรา
อสฺสตฺถรุกฺขมูลมฺหิ　　พุชฺฌิสฺสตี มหายเสา ๆ

---

๑ ฉ.ม. ปวุณฺณปวรุตฺตา ๆ ๒ ฉ. พุทฺธา ๆ

តិស្សពុទ្ធវង្ស ទី ១៣

តថាគតកាន់ផ្ការនោះ ចាំងលើព្រះសិរ្សា នៃព្រះជិនស្រីព្រះនាមតិស្សៈ ជាលោកគ្គនាយក ដែលមានបរិស័ទ ៤(១) ចោមរោម ។ ព្រះពុទ្ធអគ្គនោះ ទ្រង់គង់កណ្តាលប្រជុំជន ហើយព្យាករតថាគតកាលនោះថា ក្នុងកប្បទី ៩២ អំពីមណ្ឌកប្បនេះទៅ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះនឹងចេញពីបុរី ឈ្មោះកបិលពស្តុ ជាទីត្រកអរ ទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលចាយាសត្រង់ទីនោះ ហើយនឹងចូលទៅកាន់ស្ទឹងនេរញ្ជរ ។ ព្រះជិនស្រីអគ្គនោះ បានសោយចាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរ ហើយចូលទៅទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះពុទ្ធមានយសធំ ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ។

---

១ បានដល់ខត្តិយបរិស័ទ ១ ព្រាហ្មណបរិស័ទ ១ គហបតិបរិស័ទ ១ សមណបរិស័ទ ១ ។ អដ្ឋកថា ។

ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហោស្សតិ គោតមោ ។
កោលិតោ ឧបតិស្សោ ច អគ្គា ហោស្សន្តិ សាវកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា
អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច អគ្គា ហោស្សន្តិ សាវិកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។
ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ អគ្គា ហោស្សន្តុបដ្ឋកា ។
ឧត្តរា តា ច ឧត្តរ អគ្គា ហោស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស តោតមស្ស យសស្សិនោ ។
ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ
អាហោធិតា នរមរូ ពុទ្ធវីជង្កុរេ អយំ ។

ព្រះជននី នៃព្រះពុទ្ធនេះ ព្រះនាមមាយា ព្រះបិតាព្រះនាម
សុទ្ធោទន: តាបសនេះ ទើបបានជាព្រះពុទ្ធ ព្រះនាមគោតម ។
ព្រះកោលិត: ១ ព្រះឧបតិស្ស: ១ ទើបជាអគ្គសាវ័ក សុទ្ធតែ
មិនមានអាសវ: ប្រាសចាកភាគ: មានចិត្តស្ងប់រម្ងាប់ មាន
ចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ ទើបបម្រើព្រះ
ជិនស្រីអង្គនេះ ។ នាងខេមាថេរី ១ នាងឧប្បលវណ្ណាថេរី
១ ទើបជាអគ្គសាវិកា សុទ្ធតែមិនមានអាសវ: ប្រាសចាក
ភាគ: មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើ
សម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ គេហៅថា
អស្សត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ ជាអគ្គ-
ឧបដ្ឋាក ។ នន្ទមាតាឧបាសិកា ១ ឧត្តរាឧបាសិកា ១ ជា
អគ្គឧបដ្ឋាយិកា ព្រះគោតម មានយសអង្គនោះ ទ្រង់មាន
ព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្សនិងទេវតា បានស្តាប់
នូវព្រះពុទ្ធដីកានេះ នៃព្រះមហេសី ទ្រង់ឥតមានបុគ្គលស្មើ
ហើយរីករាយថា តាបសនេះ ជាពូជពន្ធុក នៃព្រះពុទ្ធ ។

สตฺตสเมา ตีสฺวพุทฺธวนฺทเน

ขุกฺกุฏสนฺถา วตฺตนฺติ อจฺฉาเชนฺติ มหาชนา
กตญฺญโล ชนมสฺสนฺติ ชนสมาสฺสาสเนวกา ฯ

ยทิมสฺส โลกสฺส ชนสฺส วิวฏฺฏสฺสาม สาสนํ
อนาคตมฺหิ อทฺธาเน เหสฺสาม สมฺมุขา สมํ ฯ

ยถา มนุสฺสา ชนินฺทสฺส ปฏิสนฺถาร วิวฏฺฏาย
เหฏฺฐาสนฺถา กเหตฺวาน ขตฺตนฺติ มหาชนา ฯ

ฆาเฆว มยฺหํ สพฺเพ ยทิ มุญฺจามิมํ ชนํ
อนาคตมฺหิ อทฺธาเน เหสฺสาม สมฺมุขา สมํ ฯ

ตสฺสาปิ วจนํ สุตฺวา ตายฺยา จิตฺตํ ปสาทยึ
ขตฺตา วตฺตมชฺฌาสึ ชนสงฺคหการิยา ฯ

เขมกาโม ภยา ชนกาโม ชนสงฺโค ภยา ขตฺติยา
ปตฺถนา ภยา ชนิกา ตีสฺวสฺสาธมเหสโน ฯ

តិស្សពុទ្ធវង្ស ទី ១៣

សម្ដេងហ៊ោ កំប្រព្រឹត្តទៅ ពួកមនុស្សព្រមទាំងទេវតា ទាំង
មួយម៉ឺនលោកធាតុ នាំគ្នាទះដៃ អបអរសាទរ ធ្វើអញ្ជលី
នមស្ការថា បើយើងឃ្លាងមគ្គផល ក្នុងសាសនាព្រះលោក-
នាថអង្គនេះ គង់យើងបានសម្រេច ចំពោះព្រះកក្រ្តនៃព្រះ
គោតមនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាល
ឆ្ងន់ស្ងឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាង
ក្រោម ហើយឆ្ងន់ស្ងឹងជំបាន យ៉ាងណា ពួកយើងទាំងអស់
គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេច ចំពោះ
ព្រះកក្រ្តនៃព្រះគោតមនេះ ក្នុងអនាគត យ៉ាងនោះដែរ ។
តថាគត លុះបានស្តាប់នូវព្រះពុទ្ធដីកា នៃព្រះជិនស្រីអង្គនោះ
ហើយ ធ្វើចិត្តឲ្យរឹងរឹតតែជ្រះថ្លាថែមទៀត ទំអធិដ្ឋានវត្តត
ទៅ ដើម្បីបំពេញបារមីទាំង ១០ ។ ព្រះមហេសីព្រះនាម
តិស្សៈ មានទីក្រុងឈ្មោះខេមកៈ មានព្រះមហាក្សត្រ ព្រះ
នាមជនសន្ធៈ ជាព្រះបិតា មានព្រះជននី ព្រះនាមបទុមា ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

សត្តាវស្សសហស្សានិ អតាវំ អដ្ឋាសិ សោ
កុណាសេលាជានិយនិសភោ[1] តយោ ចាសាធមុត្តមា
សមត្តឹសសហស្សានិ ជាវិយោ សមលង្កតា
សុភង្គោ ជាម សា ជាវ័ អានន្ទោ ជាម អគ្គសាវកោ ។
និមិត្តេ ចតុរោ និស្សា អស្សយោនេន និក្ខមិ
អន្ធនកំ អឌ្ឍមាសំ បជានំ បធមាំ ជិនោ ។
ព្រហ្មាជា យាចិតោ សន្តោ តិសេ្សា លោកគ្គនាយកោ
វត្តចក្កោ មហាវីរោ យសវតីនាយមុត្តមេ ។
ព្រហ្មនេរោ ច ឧនយោ ច អហោសុំ អគ្គសាវកា
សមគោ[2] ជាមុបដ្ឋាកោ តិសសុ ច មហោសិនោ ។
ឌុសេ្សា ចេវ សុនត្តា ច អហោសុំ អគ្គសាវិកា
ពោធិ តស្សភគវតោ អសនោតិ បវុច្ចតិ ។

---

๑ ម. គុហាសេលវារីនិសភា ។ ម. កុម្ភកោ នាឡ្ហិយោ ចទុមោតិ ទិស្សតិ ។ ๒ ម. សមង្គោ ។

ព្រះតិស្សៈនោះ ទ្រង់គ្រប់គ្រងព្រះរាជគេហស្ថាន អស់ ៧ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះ គុណាសេលៈ ១ ប្រាសាទឈ្មោះ អនាទិយៈ ១ ប្រាសាទឈ្មោះនិសភៈ ១ ។ ពួកនារី ចំនួន ៣ ហ្មឺននាក់ សុទ្ធសឹងតែតាក់តែងខ្លួនល្អ ឯនាងនារី ជាអគ្គមហេសីនោះ ព្រះនាមសុភទ្រា ព្រះរាជបុត្រ ព្រះនាមអានន្ទ ។ ព្រះជិនស្រីទ្រង់ឃើញនិមិត្តទាំង ៤ ក៏យាងចេញទៅ ដោយយានសេះទៅតម្កល់ព្យាយាម អស់កាលកន្ទះខែគត់ ។ ព្រះលោកនាយក ព្រះនាមតិស្សៈ ប្រសើរក្នុងលោក មានព្យាយាមធំ ត្រូវព្រហ្មអាពាធនាហើយ ទើបទ្រង់ញុាំងចក្រគឺធម៌ឲ្យប្រព្រឹត្តទៅ ក្នុងឃសវតីទាយវ័នដ៏ឧត្តម ។ ព្រះព្រហ្មទេវត្ថេរ ១ ព្រះឧទយត្ថេរ ១ ជាអគ្គសាវក កិក្ខុឈ្មោះសមគៈ ជាឧបដ្ឋាកនៃព្រះមហេសី ព្រះនាមតិស្សៈ ។ នាងផុស្សាថេរី ១ នាងសុទត្តាថេរី ១ ជាអគ្គសាវិកា ដើមឈើជាទីត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថា អសនព្រឹក្ស (ដើមធ្នង់) ។

สត្តរសមោ តំសម្ពុទ្ធវំសោ

សង្ខលោ ច សរិ(๑) ចេវ អហោសុំ អគ្គុបដ្ឋកា
តិសាតោតមី ឧបសេនោ អហោសុំ អគ្គុបដ្ឋិកា ។
សោបិ ពុទ្ធោ សដ្ឋិវស្សោ អហុ ឧច្ចត្តនេ ជិនោ
អនុបមោ អសទិសោ ហិមវា វិយ និស្សិតំ ។
តស្សាបិ អតុលតេជស្ស អាយុ អាសិ អនុត្តរោ
វស្សសតសហស្សានិ លោកេ អដ្ឋាសិ ចក្ខុមា។
ឧត្តមំ បវរំ សេដ្ឋំ អនុកោត្វា មហាយសំ
ជលិត្វា អគ្គិក្ខន្ធោវ និព្ពុតោ សោ សសាវកោ។
វិលាមាកោវ អធិលេន សុវិយេន វិយ ឧស្សវេ
អង្គកាកេវ ធីបេន និព្ពុតោ សោ សសាវកោ។
តំសេត្ថា ជិនវរោ ពុទ្ធោ ធម្មាភមម្ហិ និព្ពុតោ
តត្ថេវ តស្ស ជិនថូបោ តីណិ យោជនមុស្សិតោ(๒)។

តំសម្ពុទ្ធវំសោ សត្តរសមោ ។

---

๑ ម. សរិមា ។ ๒.ម. យោជនមុគ្គតោតិ ។

តិស្សពុទ្ធវង្ស ទី ១៣

សម្ពលគហបតី ១ សិរិគហបតី ១ ជាអគ្គុបដ្ឋាក កីសាគោតមីឧបាសិកា ១ ឧបសេនាឧបាសិកា ១ ជាអគ្គុបដ្ឋាយិកា ។ ព្រះជិនស្រីសម្ពុទ្ធនោះឯង ទ្រង់មានកំពស់ ៦០ ហត្ថ ឥតមានបុគ្គលប្រៀបផ្ទឹមបាន ឥតមានបុគ្គលស្មើបាន ប្រាកដដូចភ្នំហិមពាន្ត ។ ព្រះជិនស្រីអង្គនោះ ទ្រង់មានតេជះថ្លឹងពុំបាន ទ្រង់មានព្រះជន្ម មួយសែនឆ្នាំ ព្រះអង្គមិនមានបុគ្គលក្រៃលែងជាង ទ្រង់មានចក្ខុ បិតនៅក្នុងលោក ។ ព្រះជិនស្រីអង្គនោះ ព្រមទាំងសាវ័ក ទ្រង់សោយនូវយសធំដ៏ឧត្តម ប្រសើរ រុងរឿងដូចគំនរភ្លើង ហើយបរិនិព្វាន ។ ព្រះជិនស្រីអង្គនោះ ព្រមទាំងសាវ័ក ទ្រង់បរិនិព្វានហើយ ដូចជាភ្លៀង (ដែលបាត់ទៅ) ព្រោះខ្យល់ ឬដូចទឹកសន្ទៃមែ (អស់ទៅ) ព្រោះព្រះអាទិត្យ ឬដូចឆ្ងឹត (បាត់ទៅ) ព្រោះប្រទីប ។ ព្រះពុទ្ធព្រះនាមតិស្សៈ ជាព្រះជិនស្រីដ៏ប្រសើរ បរិនិព្វានក្នុងនន្ទារាម ព្រះស្តូបព្រះជិនស្រីអង្គនោះ ពួកមហាជនសាងទុក កំពស់ ៣ យោជន៍ ក្នុងនន្ទារាមនោះ ។

បាប់ តិស្សពុទ្ធវង្ស ទី ១៣ ។

អដ្ឋារសមោ បុស្សពុទ្ធវំសោ

(១៩) តស្សោ មណ្ឌកប្បម្ហិ អាហុ សត្ថា អនុត្តរោ
អនុបមោ អសមសមោ បុស្សោ លោកគ្គនាយកោ។

សោបិ សព្ពំ តមំ ហន្ត្វា វិធមេត្វា មហាភយំ
សន្ទេវកំ តម្បយន្តោ អភិវស្សិ អមតម្ពុនា ។

ធម្មចក្កំ បវត្តេន្តោ ឧប្បន្នេ ធម្មគ្គមន្តលេ
អសីតិសតសហស្សានំ បឋមាភិសមយោ អហុ ។

ទុតិយាភិសមយោ អហុ ទ្វេនវុតិសតសហស្សានំ
តតិយាភិសមយោ អហុ អសីតិសតសហស្សានំ។

សន្និបាតា តយោ អាសុំ បុស្សស្ស ច មហេសិនោ
ខីណាសវានំ វិមលានំ សន្និចិតានេ តាទិនំ ។

សន្និសតសហស្សានំ បឋមោ អាសិ សមាគមោ
បញ្ញាសសតសហស្សានំ ទុតិយោ អាសិ សមាគមោ។

បុស្សពុទ្ធវង្ស ទី ១៨

(១៩) ក្នុងមណ្ឌកប្បនោះឯង មានព្រះសាស្តា ព្រះនាមបុស្សៈ ទ្រង់មិនមានបុគ្គលក្រៃលែងជាង មិនមានបុគ្គលប្រៀបផ្ទឹមបាន ស្មើដោយព្រះពុទ្ធដែលមិនមានបុគ្គលស្មើ ជានាយកប្រសើរ ក្នុងលោក ។ ព្រះពុទ្ធអង្គនោះ ទ្រង់កំចាត់បង់ធំងឆឹតទាំងអស់ ហើយត្រដោះគ្រឿងចាក់ស្រែះធំ (កិលេស) ទ្រង់ញុាំងមនុស្សព្រមទាំងទេវតា ឲ្យឆ្អែតស្កប់ស្កល់ ទ្រង់បង្អុរភ្លៀងទឹកអម្រឹតចុះមក ។ កាលព្រះពុទ្ធ ព្រះនាមបុស្សៈ ញុាំងចក្រគឺធម៌ ឲ្យប្រព្រឹត្តទៅ ការត្រាស់ដឹងលើកទី ១ មានពួកសត្វ ៨០ សែន ក្នុងមង្គលនៃថ្ងៃនក្ខត្តឫក្ស ។ ការត្រាស់ដឹងលើកទី ២ មានពួកសត្វ ៩០ សែន ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៨០ សែន ។ ព្រះមហេសី ព្រះនាមបុស្សៈ មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាពួកព្រះខីណាស្រពតគមានមន្ទិលគឺកិលេស មានចិត្តស្ងប់រម្ងាប់ ប្រកបដោយគុណ ។ សន្និបាតលើកទី ១ មានព្រះខីណាស្រព ៦០ សែន សន្និបាតលើកទី ២ មានព្រះខីណាស្រព ចំនួន ៥០ សែន ។

អដ្ឋារសមោ បុស្សវិសោ

ចត្តាទ្បីសសតសហស្សានំ តតិយោ អាសិ សមាគមោ
អនុថាតា វិមុត្តានំ ភេច្ឆន្នបដិសម្ភិទំ ។
មហាឥន្ទេន សមយេន វិជិតោ ជាម(๑) ទត្តិយោ
ឆឌ្ឌយិត្វា មហារជ្ជំ បព្ភជឺ តស្ស សន្តិកេ ។
សោបិ មំ ពុទ្ធោ ព្យាកាសិ បុស្សោ លោកក្ត-
ជាយតោ
ទ្វេនវុតេ ឥតោ កប្បេ អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បធហិត្វាន កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មឺ និសីទិត្វា តថាគតោ
តត្ថ ថាយាសំ បក្ខន្ទោ នេរញ្ជរមុបេហិតំ ។
នេរញ្ជរាយ តីរម្ហិ ថាយាសំ អធិ សោ ជិនោ
បដិយត្តវរមក្កេន ពោធិមូលម្ហិ ឋហិតំ ។

---

๑ ឧ. ម. វិជិតាវី តាម ។

បុស្សពុទ្ធវំសៈ ទី ១៨

សន្និបាតលើកទី ៣ មានពួកព្រះខីណាស្រព ៤០ សែន លោកផុតស្រឡះហើយ ព្រោះមិនប្រកាន់ មានដំណាគឺជាតិ កាត់ផ្តាច់ហើយ ។ សម័យនោះ តថាគតជាកូត្រ ព្រះនាមវិជិតៈ លះចោលរាជសម្បត្តិដ៏ធំ ទៅបួសក្នុងសំណាក់ព្រះពុទ្ធនោះ ។ ព្រះពុទ្ធជាម្ចាស់ ព្រះនាមបុស្សៈ ជាលោកគ្គនាយកនោះ បានទ្រង់ព្យាករតថាគតថា ក្នុងកប្បទី ៩២ អំពីកប្បនេះទៅ កិក្ខុនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីកបិលពស្តុបុរី ជាទីរីករាយ ទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលជ័យសក្នុងទីនោះ ហើយចូលទៅកាន់ស្នឹងនេរញ្ជរ ។ ព្រះជិនស្រីអង្គនោះ បានសោយជ័យាស ទៀបឆ្នេរស្នឹងនេរញ្ជរ ហើយស្តេចទៅឯគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។

តតោ បធក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។
ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហោស្សតិ គោតមោ ។
កោលិតោ ឧបតិស្សោ ច អគ្គា ហោស្សន្តិ សាវកា
អនាសវា វីតភយា សន្តចិត្តា សមាហិតា
អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច អគ្គា ហោស្សន្តិ សាវិកា
អនាសវា វីតភយា សន្តចិត្តា សមាហិតា ។
ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថិទ្យវកោ អគ្គា ហោស្សន្តុបដ្ឋកា ។
ឧត្តរា នា ច ឧត្តរ អគ្គា ហោស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។

លំដាប់នោះ ព្រះពុទ្ធមានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈ ដ៏ប្រសើរ ហើយត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះជននី នៃព្រះពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ កិក្ខុនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ឧបតិស្សៈ ១ នឹងជាអគ្គសាវ័ក សុទ្ធតែមិនមានអាសវៈ ប្រាសចាកពាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ កិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ ។ ខេមាកិក្ខុនី ១ ឧប្បលវណ្ណាកិក្ខុនី ១ នឹងជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាកពាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើជាទីត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតម មានយសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។

អដ្ឋារសមោ បុស្សពុទ្ធវំសោ

ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ
អាមោទិតា នរមរូ ពុទ្ធវីរង្កុរោ អយំ ។
ខុក្កុដិសង្ខា វត្តន្តិ អច្ឆោជេន្តិ មហន្តិ ច
កតញ្ជលី នមស្សន្តិ ឥសិសហស្សឹ សនេវកា ។
យទិមស្ស លោកជេដ្ឋស្ស វិវដ្ដិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា កិរិយ្យា ចិត្តំ បសាទយឹ
ខត្តិរំ វត្តមជ្ឈាសឹ ឥសចារមិហូរិយា ។
សុត្តន្តំ វិនយញ្ចាបិ ជាតិសត្ថុសាសនំ
សព្ពំ បរិយាបុណិត្វាន សោកយឹ ជិនសាសនំ ។
តត្ថបប្ផមត្តោ វិហរន្តោ ព្រហ្មំ ការេត្វា ការំ
អភិញ្ញាសុ ចារមឹ កត្វា ព្រហ្មលោកមភញ្ជិហំ ។

ពួកមនុស្សទ្រនិងទៅតា លុះឮព្រះពុទ្ធដីកានេះ នៃព្រះមហេសី
ឥតមាមានបុគ្គលស្មើហើយ ក៏រីករាយថា កិក្ខុនេះ ជាពូជពន្ធុក
នៃព្រះពុទ្ធ ។ សម្តេងហោ៏ក៏ប្រព្រឹត្តទៅ ពួកមនុស្សទ្រនិងទៅតា
ចាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា
បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនា នៃព្រះលោកនាថ
អង្គនេះ គង់នឹងសម្រេច ក្នុងទីចំពោះព្រះកក្កុ នៃព្រះគោតម
នេះ ក្នុងកាលអនាគតមិនខាន ។ ចំណែកខាងតថាគត បាន
ស្តាប់ព្រះពុទ្ធដីកា នៃព្រះបុស្សសម្ពុទ្ធនោះហើយ ក៏ញុំាងចិត្តឲ្យ
រីងរឹតតែជ្រះថ្លា ហើយទំអធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញ
បារមីចាំង ១០ ប្រការ ។ តថាគត រៀនយកនូវព្រះសូត្រផង
ព្រះវិន័យផង ពាក្យប្រៀនប្រដៅព្រះសាស្តា ប្រកបដោយអង្គ
៩ ចាំងអស់ផង ហើយញុំាងសាសនាព្រះជិនស្រីឲ្យរុងរឿង ។
តថាគតមិនប្រមាទ សម្រេចសម្រាន្តនៅក្នុងសាសនានោះ ទំ
ចម្រើនភាវនា ដែលប្រកបដោយព្រហ្មវិហារ ហើយដល់នូវ
បារមីកន្លងអកិញ្ចាចាំងឡាយ ហើយទៅកើតក្នុងព្រហ្មលោក ។

สุตฺตนฺตปิฏกេ ขុទ្ទកនិកាយស្ស ពុទ្ធវំសោ

តាសំ កំ នាម នគរំ ជយសេនោ នាម ខត្តិយោ
សិរិមា នាម ជនិកា បុសฺสสฺส ច មហេសិនោ ฯ
ឆវสฺสสหสฺสานิ អតานំ អដฺฐาสิ เสา
กุฏฺฐมหาสสุวณฺณาภา តយោ ចาสาธมุตฺตมา ฯ
เตรีสតีสหสฺสานิ ชาโย สมลงฺกตา
กีสาโคตมี นามาสิ อานนฺโท นาม อตฺรโช ฯ
นิมิตฺเต จตุเร ทิสฺวา ภเตฺวยาเนน นิกฺขมิ
สตฺตาหំ បធานจารំ อจរิ បุริสุตฺตโม ฯ
ព្រហฺมา យาจิโต สนฺโต ปุเสฺสา โลกคฺค-
นายโก
វត្តจกฺกំ មหาវีโร มิคทายេ ปวตฺตยิ ฯ
สุรกฺขิโต ច นฺหาสเนา อโหสุំ អគฺคสาวกา
สกิเยฺยา นาม อุបដฺฐาโก បุสฺสสฺส ច มหេសิនោ ฯ

ព្រះមហេសី ព្រះនាមបុស្សៈ មានទីក្រុង ឈ្មោះកាសិកៈ មានមហាក្សត្រ ព្រះនាមជយសេន ជាព្រះបិតា មានព្រះជននី ព្រះនាមសិរិមា ។ ព្រះបុស្សៈនោះ ទ្រង់គ្រប់គ្រងគេហដ្ឋាន អស់ ៩ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះគុរុឡ ១ ប្រាសាទឈ្មោះហំសៈ ១ ប្រាសាទឈ្មោះសុវណ្ណតារៈ ១ ។ ពួកនារី ៤៣ ពាន់ សំដែងខ្លួនតាក់តែងល្អហើយ ឯនារី ជាអគ្គមហេសី ឈ្មោះកីសាគោតមី ព្រះពុទ្ធបុត្រឈ្មោះអានន្ទ ។ ព្រះជិនស្រី ជាបុរសដ៏ប្រសើរ ទ្រង់ទតឃើញនិមិត្តទាំង ៤ យ៉ាង ហើយចេញទៅដោយយានដ៏រី បានប្រព្រឹត្តធ្វើព្យាយាម អស់ ៧ ថ្ងៃ ។ ព្រះលោកគ្គនាយក ព្រះនាមបុស្សៈ មានព្យាយាមធំ ទ្រង់ប្រសើរជាងជន ត្រូវព្រហ្មអាពាធនាហើយ ទើបទ្រង់ញុំាងចក្រគឺធម៌ ឲ្យប្រព្រឹត្តទៅ នាវៃព្រមិគទាយវ័ន ។ ព្រះសុវត្ថិតភិក្ខុ ១ ព្រះធម្មសេនភិក្ខុ ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះសភិយៈ ជាឧបដ្ឋាក នៃព្រះមហេសី ព្រះនាមបុស្សៈ ។

អដ្ឋារសមោ បុស្សពុទ្ធវំសោ

ចាលា ច ឧបចាលា ច អហោសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ អាមលកោតិ វុច្ចតិ ។
អនញ្ញយោ វិសាខោ ច អហោសុំ អគ្គុបដ្ឋកា
បទុមា សិរិមា ច អហោសុំ អគ្គុបដ្ឋិកា ។
អដ្ឋបណ្ណាសរតនំ សោបិ អច្ចុគ្គតោ មុនិ
សោភតិ សតរំសីវ ឧទ្ធុកជាវ ភូរិតោ ។
ឆត្តិវស្សសហស្សានិ អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនកំ ពហុំ ។
ឱវទិត្វា ពហូ សត្តេ សន្តារេត្វា ពហូ ជនេ
សោបិ សត្ថា អតុលយសោ ឯកូនោ សោ សសាវកោ។
បុរេស្សា ជិនរាកេ សត្តា សេនាភមិ្ហ ឯកូនោ
ជាតុវិត្តារកំ អាសិ តេសុ តេសុ បទេសតោតិ។

បុស្សពុទ្ធវំសោ អដ្ឋារសមោ។

បុស្សពុទ្ធវង្ស ទី ១៨

នាងចាលាកិក្ខុនី ១ នាងឧបចាលាកិក្ខុនី ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ គេហៅថា អាមលកព្រឹក្ស (ដើមកន្ធូតព្រៃ) ។ អនញ្ញគហបតី ១ វិសាខគហបតី ១ ជាអគ្គឧបដ្ឋាក នាងឧបមា ១ នាងសិរិនាគា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមុនីអង្គនោះ មានកំពស់ ៥៨ ហត្ថ ទ្រង់រុងរឿងដូចព្រះអាទិត្យ ឬដូចព្រះចន្ទ្រពេញវង់ ។ ទ្រង់មានព្រះជន្ម ៩០ ពាន់ឆ្នាំ ព្រះអង្គកាលទ្រង់ធរមាននៅឡើយ បានចម្រើនប្រជុំជនជាច្រើន ។ ព្រះសាស្តាអង្គនោះ ព្រមទាំងសាវ័ក ទ្រង់មានយសថ្កើងពុំបាន ទ្រង់ទូន្មានពួកសត្វជាច្រើន ហើយចម្រើនពួកសត្វជាច្រើន រួចបរិនិព្វាន ។ ព្រះដ៏ន្ទសីដ៏ប្រសើរ ព្រះនាមបុស្សៈ ទ្រង់ជាសាស្តា បរិ-ព្វានហើយក្នុងសេនាភម ការផ្សាយចេញទៅ នៃព្រះធាតុមានក្នុងប្រទេសទាំងឡាយនោះ ។ ។

ចប់ បុស្សពុទ្ធវង្ស ទី ១៨ ។

ឯកូនវីសតិមោ វិបស្សីពុទ្ធវំសោ

(២០) បុស្សស្ស អបរេន សម្ពុទ្ធោ ឥបទុត្តមោ

វិបស្សី នាម នាមេន លោកេ ឧប្បជ្ជិ ចក្ខុមា។

អវិជ្ជណ្ឌំ បទាលេត្វា បត្តោ សម្ពោធិមុត្តមំ

ធម្មចក្កំ បវត្តេតុំ បក្កាមិ ពន្ធុមតីបុរំ ។

ធម្មចក្កំ បវត្តេត្វា ឧភោ ពោធេសិ នាយកោ

កណាជាយ ន វត្តញ្ញោ បឋមាភិសមយោ អហុ។

បុនាបរំ អភិតយសោ តត្ត សង្ឃំ បកាសយិ

ចតុរាសីតិសហស្សានំ ខុតិយាភិសមយោ អហុ។

ចតុរាសីតិសហស្សានិ សម្ពុទ្ធមនុបព្ភុំ

តេសមាភមបត្តានំ ឆម្ភំ ឧេសេសិ ចក្ខុមា ។

វិបស្សីពុទ្ធវង្ស ទី ๑๙

(๒๐) ក្រោយអំពីព្រះពុទ្ធ ព្រះនាមបុស្សៈមក មានព្រះសម្ពុទ្ធ ព្រះនាមវិបុស្សី ដ៏ឧត្តមជាងសត្វដើងពីរ ទ្រង់មានចក្ខុកើតឡើង ក្នុងលោក ។ ព្រះអង្គទ្រង់រំលាយសុំគ គឺអវិជ្ជាចេញ ហើយដល់សម្ពោធិញ្ញាណដ៏ឧត្តម ទ្រង់ចៀសចេញទៅកាន់ពន្ធុមតីបុរី ដើម្បីញ៉ាំងចក្រគឺធម៌ ឲ្យប្រព្រឹត្តទៅ ។ ព្រះនាយក ទ្រង់ញ៉ាំងចក្រគឺធម៌ ឲ្យប្រព្រឹត្តទៅ រួចហើយញ៉ាំងខណ្ឌភជកុមារនិងតិស្សកុមារទាំងពីរ ឲ្យត្រាស់ដឹង ការត្រាស់ដឹងលើកទី ๑ មានចំនួនសត្វ គេមិនគប្បីពោលដោយការរាប់ឡើយ ។ តមកទៀត ព្រះពុទ្ធជាម្ចាស់ មានយសរាប់មិនបាន ប្រកាសសច្ចៈទាំង ๔ ក្នុងបុរីនោះ ការត្រាស់ដឹងលើកទី ๒ មានពួកសត្វ ចំនួន ๘ ហ៊ឺន ๔ ពាន់ ។ មានមនុស្ស ๘ ហ៊ឺន ๔ ពាន់ បួសតាមព្រះពុទ្ធ ព្រះពុទ្ធមានចក្ខុទ្រង់សម្លែងធម៌ដល់បព្វជិតទាំងនោះ ដែលមកដល់អាស្រម ។

ឯកូនវិសតិមោ វិបស្សីពុទ្ធវំសោ

សព្ពាការេន អាសតោ ឋត្វា(១) ឧបនិសជ្ជ ដិនោ
តេបិ ឆឌ្ឌេវ៌ំ កត្វា តតិយាភិសមយោ អហុ ។
សន្និចាតា តយោ អាសុំ វិប្ផស្សិស្ស មហេសិនោ
ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។
អដ្ឋសដ្ឋិសតសហស្សានំ(២) បឋមោ អាសិ សមាគមោ
តេត្តិំសតសហស្សានំ ទុតិយោ អាសិ សមាគមោ ។
អសីតិកោដិសហស្សានំ តតិយោ អាសិ សមាគមោ
តត្ថ តេត្តិំកណាមជ្ឈ សម្ពុទ្ធោ អតិរោចតិ ។
មហាឆត្តេន សមយេន ជាតភាជា មហិទ្ធិកោ
អតុលោ ជាម ជាមេន បុញ្ញវន្តោ ជុតិន្ធរោ ។
ឆេតានំ ជាតកោដីនំ បវរោ វេស្សានហំ តទា
វជ្ជន្តោ ទិព្ពតុរិយេហិ លោកជេដ្ឋំ ឧបាគមិ ។

---

១ ឧ. ម. សុត្វា ។ ២ ឧ. អដ្ឋសដ្ឋិសហស្សានំ ។

ភិក្ខុ៣ាំង៤នោះ អាស្រ័យព្រះជិនស្រី កាលទ្រង់សម្តែង៤ដោយ
អាការ៣ាំង៣ួង កំ៉ុង៤សម្រេចទូវែង៤ដ៏ប្រសើរ នេះជាការត្រាស់
ដឹង៤លើក៤ទី ៣ ។ ព្រះមហេសី ព្រះនាមវិបស្សី មាន៤សាវក-
សន្និបាត ៣ លើក ដែលសុទ្ធ៤តែ៣ួកព្រះខីណាស្រព ឥតមាន
មន្ទិលគឺកិលេស មាន៤ចិត្តស្ងប់រម្ងាប់ ប្រកប៤ដោយតាទិគុណ ។
គឺសន្និបាត៤លើក៤ទី ១ មាន៣ួកព្រះខីណាស្រព ចំនួន ៦៨ សែន
សន្និបាត៤លើក៤ទី ២ មាន៣ួកព្រះខីណាស្រព ចំនួន៣ួយសែន ។
សន្និបាត៤លើក៤ទី ៣ មានភិក្ខុចំនួន ៨ ហ្មឺន ព្រះសម្ពុទ្ធ៤ុង៤រឿង
ក្នុង៤ណ្តាល៣ួក៤ភិក្ខុ៤នោះ ។ សម័យ៤នោះ ត៤ាគត៤កើត៤ជាស្តេច
នាគ ឈ្មោះអតុល: មានឫទ្ធិច្រើន មានបុណ្យ ទ្រទ្រង់ពន្ធឺ ។
ក្នុង៤កាល៤នោះ ត៤ាគត មាន៣ួកនាគច្រើន៤តាដ៏ ចោមរោម
ប្រគំតូរ្យតន្ត្រីដ៏ជាជាទិព្វ ហើយចូល៤ៅដ៏ត៤ព្រះលោក៤ដ៏ដ: ។

ឧបសង្កមិត្វាន សម្ពុទ្ធំ វិបស្សិំ លោកនាយកំ

មណិមុត្តារតនូបធិតំ សព្ពាការសោភិតំ

ឯមន្តេត្វា ឆឌ្ឌាភិសម្ពុ សុវណ្ណាបិឋមធាសហំ ។

សោបិ មំ ពុទ្ធោ ព្យាការសិ សង្ឃមជ្ឈេ និសីទិយ

ឯកនវុតិ ឥតោ កប្បេ អយំ ពុទ្ធោ ភវិស្សតិ ។

អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ

បធានំ បធហិត្វាន ភត្វា ពុទ្ធភារាភំ ។

អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ

តត្ត ចាយាសំ បក្ខិយ្ហា នេរញ្ជរមុបេហិតំ ។

នេរញ្ជាយ តីរម្ហិ ចាយាសំ អទិ សោ ជិនោ

បដិយត្តវរមក្កេន ពោធិមូលម្ហិ ឯហិតំ ។

លុះបួលទៅដល់ហើយ ក៏និមន្តព្រះសម្ពុទ្ធ ព្រះនាមវិបស្សី ជាលោកនាយក ហើយថ្វាយតាំងមាស ដែលដាំដោយកែវមណី និងកែវមុក្តា ដ៏ស្អិតស្អាងហើយដោយអាការៈគ្រប់យ៉ាង ដល់ព្រះអង្គជាធម្មរាជ ។ ព្រះពុទ្ធជាម្ចាស់នោះ ទ្រង់គង់នៅក្នុងកណ្តាលសង្ឃ ហើយព្យាករតថាគតថា ក្នុងកប្បទី ៩១ អំពីមណ្ឌកប្បនេះ ស្តេចនាគនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញពីកបិលពស្តុបុរី ជាទីត្រេកអរ ទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយខៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយបួលទៅកាន់ស្នឹងនេរញ្ជរ ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាស ខៀបឆ្នេរស្ទឹងនេរញ្ជរ ហើយបួលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។

តតោ បឧក្ខិណាំ កត្វា ពោធិមណ្ឌំ អនុត្តរំ

អស្សត្ថម្ហលេ សម្ពោធិំ ពុជ្ឈិស្សតិ មហាយសោ ។

៥មស្ស ជនិកា មាតា មាយា ជាម ភវិស្សតិ

បិតា សុទ្ធោទនោ ជាម អយំ ហោស្សតិ គោតមោ ។

កោលិតោ ឧបតិស្សោ ច អគ្គា ហោស្សន្តិ សាវកា

អជាសកា រីតរកា សន្តចិត្តា សមាហិតា

អានន្ទោ ជាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។

ខេមា ឧប្បលវណ្ណា ច អគ្គា ហោស្សន្តិ សាវិកា

អជាសកា រីតរកា សន្តចិត្តា សមាហិតា ។

ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ

ចិត្តោ ច ហត្ថាឡវកោ អគ្គា ហោស្សន្តុបដ្ឋកា ។

ឧត្តរា តាបសី ច ឧត្តរា អគ្គា ហោស្សន្តុបដ្ឋិកា

អាយុ វស្សសតំ តស្ស គោតមស្សេវ សាសនោ ។

លំដាប់នោះ ព្រះពុទ្ធមានយសធំ ធ្លើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ដឹងនូវសម្ពោធិញ្ញាណ ទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះជននី នៃព្រះពុទ្ធនេះ ព្រះនាមមាយា ព្រះបិតា ព្រះនាមសុន្ទោទនៈ នាគរាជនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងជាអគ្គសាវ័ក សុទ្ធតែមិនមានអាសវៈ ប្រាសចាកភពៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ កិត្តិជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ ។ នាងខេមាកិក្ខុនី ១ នាងឧប្បលវណ្ណាកិក្ខុនី ១ នឹងជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាកភពៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ។ ដើមឈើជាទីត្រាស់ដឹង នៃព្រះមានជោគអង្គនោះ ហៅថាអស្សត្ថព្រឹក្ស បិត្តគហបតី ១ ហត្ថាឡវកគហបតី ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះមហេសីព្រះនាមគោតមនោះ មានជន្មាយុ ១០០ ឆ្នាំ ។

សុត្តន្តបិដកៈ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ
អាមោទិតា ឥរមរូ ពុទ្ធវីរង្កុរោ អយំ ។
ខុក្កុដ្ឋិសង្ខា វត្តន្តិ អច្ឆោជន្តិ ហាសន្តិ ច
កតញ្ជលី ឧមសន្តិ ឧសសហស្សី សទេវកា ។
យទិមស្ស លោកជាដស្ស រាជ្ជំ សព្ភ សាសនំ
អជាកតម្ហិ អទ្ធានេ ហេស្សតិ សម្មា ឥមំ ។
យថា មធុស្ស ឧទិ តារកា បដិតិដ្ឋំ រាជ្ជិយ
ហេដ្ឋាតិដ្ឋំ កហេត្វាន ខុត្តរន្តិ មហាឧទិ ។
ឯវមេវ មយំ សព្ពេ យទិ មុញ្ចាមិមំ ជិនំ
អជាកតម្ហិ អទ្ធានេ ហេស្សតិ សម្មា ឥមំ ។
ឥស្សាមិ វចនំ សុត្វា កិយ្យា ចិត្តំ មសាឧយិ
ខុត្តរំ វត្តមជ្ជាសិ ឧសចារមិប្បរិយា ។

ពួកមនុស្សទេវតា លុះបានស្តាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសី ឥតមានបុគ្គលស្មើ ហើយពោលយ៉ាថា នាគរាជនេះជាពូជពន្ធុកនៃព្រះពុទ្ធ ។ សម្តេចហ្នឹង ក៏ប្រព្រឹត្តទៅ ពួកមនុស្សព្រមទាំងទេវតា ទាំងមួយហ្មឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើពួកយើងឃ្លាងមគ្គផលក្នុងសាសនាព្រះលោកនាថអង្គនេះ គង់នឹងសម្រេចក្នុងទីបំពោះព្រះកត្តុនៃព្រះគោតមនេះ ក្នុងអនាគតកាល ជាមិនខាន ។ ពួកមនុស្សកាលធ្វើសឹង បើឃ្លាងកំពង់បំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយធ្វើសឹងធំបាន យ៉ាងណាមិញ ។ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់បានសម្រេចក្នុងទីបំពោះព្រះកត្តុ នៃព្រះគោតមនេះ ក្នុងអនាគតកាល យ៉ាងនោះដែរ ។ តថាគតបានស្តាប់ព្រះពុទ្ធដីកា នៃព្រះជិនស្រីអង្គនោះ ហើយញុំាងចិត្តឲ្យរីករាយត្រេកអរ បានចំអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ប្រការ ។

ឯកូនវិសតិមោ វិបស្សិពុទ្ធវំសោ

ឧភវំ ពន្ធុមតី ជាម ពន្ធុមោ ជាម ខត្តិយោ
មាតា ពន្ធុមតី ជាម វិបស្សិស្ស មហេសិនោ ។

អដ្ឋាសុ្សសហស្សានិ អភាវំ អដ្ឋាវំសំ សោ
ឧណ្ហោ សុឧណ្ហោ សិរីមា តយោ ភាសាឧមុត្តមា ។

តិចត្តារិសហស្សានិ ជាវិយោ សមលង្កតា
សុឧសុ្សជា ជាម ជាវី សមវត្តក្ខន្ធោ ជាម អគ្រជោ។

ជិមិត្តេ ចតុរោ ធិស្សា វជយានេន ជិក្ខមិ
អន្ធឧអដ្ឋមាសានិ បជានំ បធហី ជិនោ ។

ព្រហ្មាជា យាចិតោ សន្តោ វិបស្សីលោកជាយកោ
វត្តចក្កោ មហាវីរោ មិគជាយេ ឧរុត្តមោ ។

ខណ្ឌោ ច តិសុ្សជាមោ ច អហេសុំ អគ្គសាវកា
អាសោកោ ជាមុបដ្ឋាកោ វិបស្សិស្ស មហេសិនោ។

វិបស្សីពុទ្ធវង្ស ទី ១៩

ព្រះមហាសីព្រះនាមវិបស្សី មានទីក្រុងឈ្មោះពន្ធុមតី មាន
មហាក្សត្រ ព្រះនាមពន្ធុមៈ ជាព្រះបិតា មានព្រះមាតា ព្រះ
នាមពន្ធុមតី ។ ព្រះវិបស្សីអង្គនោះ ទ្រង់គ្រប់គ្រងគេហដ្ឋាន
អស់ ៨ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទ
ឈ្មោះនន្ទៈ ១ ប្រាសាទឈ្មោះសុនន្ទៈ ១ ប្រាសាទឈ្មោះ
សិរិមៈ ១ ។ ពួកនារី ចំនួន ៤ ហ្មឺន ៣ ពាន់ សឹងមានខ្លួន
តាក់តែងល្អ ឯនារីជាអគ្គមហេសី ព្រះនាមសុទស្សនា ព្រះ
រាជបុត្រ ព្រះនាមសមវត្តក្ខន្ធ ។ ព្រះជិនស្រីទ្រង់ឃើញនិមិត្ត
៤ ហើយចេញទៅដោយយានរថ តម្កល់ព្យាយាម អស់ ៨
ខែគត់ ។ ព្រះវិបស្សីជាលោកនាយក ទ្រង់មានព្យាយាមធំ
ប្រសើរជាងជន ត្រាស់ព្រហ្មអារាធនាហើយ ទើបញ៉ាំងធម្មចក្រ
ឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ។ ព្រះរាជកុមារនាមខន្ធៈ ១
បុត្រនៃបុរោហិតនាមតិស្សៈ ១ ជាអគ្គសាវ័ក កិក្ខុឈ្មោះ
អសោក ជាឧបដ្ឋាក នៃព្រះមហាសី ព្រះនាមវិបស្សី ។

ពន្ធា ច ពន្ធមិត្តា ច អហោសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ ថាដលីតិ បវុច្ចតិ ។
បុនព្ភូសុមិត្តោ ជាតោ ច អហោសុំ អគ្គុបដ្ឋកា
សិរិមា ឧត្តរា ចេវ អហោសុំ អគ្គុបដ្ឋិកា ។
អសីតិហត្ថមុព្ភេធោ រិបស្សី លោកជាយកោ
បភា និន្នាវតី តស្ស សមគ្គា សត្តយោជនេ ។
អសីតិវស្សសហស្សានិ អាយុ ពុទ្ធស្ស តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។
ពហុនោមនុស្សានំ ពន្ធនំ បរិមោចយិ
មគ្គាមគ្គញ្ញូ អាចិក្ខិ អវសេសបុថុជ្ជនេ ។
អាលោកំ ទស្សយិត្វាន ទេស្សត្វា អមតំ បទំ
ជលិត្វា អគ្គិក្ខន្ធោវ និព្ពុតោ សោ សសាវកោ ។

នាងចន្ទាកិក្ខុនី ១ នាងចន្ទមិត្តាកិក្ខុនី ១ ជាអគ្គសាវិកា ដើមឈើ
ជាទីត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថា បាដលិ-
ព្រឹក្ស ។ បុនព្វសុមិត្តគហបតី ១ នាគគហបតី ១ ជាអគ្គ-
ឧបដ្ឋាក នាងសិរិមា ១ នាងឧត្តរា ១ ជាអគ្គឧបដ្ឋាយិកា ។
ព្រះវិបស្សី លោកនាយក មានកំពស់ ៨០ ហត្ថ ពន្លឺព្រះអង្គ
ផ្សាយចេញទៅជុំវិញ ៧ យោជន៍ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មាន
ព្រះជន្ម ៨ ហ្មឺនឆ្នាំ ព្រះអង្គកាលទ្រង់ធរមាននៅឡើយ បាន
បម្រុងប្រជុំជនច្រើន ចាកសំសារវដ្ត ។ ព្រះអង្គទ្រង់ដោះស្រាយ
នូវចំណងនៃទេវតានិងមនុស្សជាច្រើន ទាំងប្រាប់ផ្លូវត្រូវផ្លូវខុស
ចំពោះពួកបុថុជ្ជនដ៏សេសទៀតផង ។ ព្រះអង្គព្រមទាំងសាវ័ក
ទ្រង់សម្តែងពន្លឺ ហើយបង្ហាញឲ្យចាយ ជាទីទៅកាន់ព្រះនិព្វាន
ឈ្មោះអមតៈ ទ្រង់រុងរឿងដូចគំនរភ្លើង ហើយបរិនិព្វាន ។

វិសតិមោ សិទ្ធិពុទ្ធវំសោ

ឥទ្ធិវរំ បុញ្ញវរំ លក្ខណាចក្កសុមិតំ
សព្ពំ សមន្តរហិតំ ឆន្ទុ វត្តា សព្ពសង្ខាតិ។
វិបស្សី នរវរោ វីរោ សុមិត្តាភមិ្ហ និព្ពុតោ
តត្ថេវ តស្ស ថូបវរោ សត្តយោជនមុស្សិតោតិ ។

វិបស្សិពុទ្ធវំសោ ឯកូនវីសតិមោ ។

វីសតិមោ សិទ្ធិពុទ្ធវំសោ

(២០) វិបស្សិស្ស អបរេន សម្ពុទ្ធោ ទិបទុត្តមោ
សិទ្ធិយោ នាម ជិនោ អសមោ អប្បដិបុគ្គលោ។
មារសេនំ បមទ្ទិត្វា បត្តោ សម្ពោធិមុត្តមំ
ធម្មចក្កំ បវត្តេសិ អនុកម្បាយ ចាណិនំ ។
ធម្មចក្កំ បវត្តេន្តេ សិទ្ធិមិ្ហ ជិនបុង្គវេ
កោដិសតសហស្សានំ បឋមាភិសមយោ អហុ ។

ព្រះសរីរៈ ដែលមានបុទ្ធិដ៏ខ្ពង់ខ្ពស់ មានបុណ្យដ៏ប្រសើរ ប្រជាប់ហើយដោយលក្ខណៈគឺចក្រ គង់ចាត់បង់អស់ទៅបាន ឧហ្ន៎ ! សង្ខារទាំងអស់ សោះសូន្យ ទទេតើ ! ព្រះវិបស្សីជានរៈដ៏ប្រសើរ ទ្រង់មានព្យាយាម បរិនិព្វានហើយ ក្នុងសុមិត្តារាម ព្រះស្តូបដ៏ប្រសើរ របស់ព្រះអង្គនោះ គេបានសាងទុក កំពស់៧យោជន៍ ក្នុងអារាមនោះ ។

ចប់ វិបស្សីពុទ្ធវង្ស ទី ១៩ ។

សិខិពុទ្ធវង្ស ទី ២០

(២១) ក្រោយព្រះពុទ្ធវិបស្សីមក មានព្រះសម្ពុទ្ធព្រះនាមសិខីជិនស្រី ទ្រង់ទត្តមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើឥតមានបុគ្គលប្រៀបផ្ទឹមបាន ។ ព្រះអង្គកំចាត់បង់សេនានៃមារ ហើយដល់សម្ពោធិញាណដ៏ប្រសើរ ញុំាងចក្រគឺធម៌ឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីអនុគ្រោះដល់ពួកសត្វ ។ កាលព្រះសិខីជិនស្រីដ៏ប្រសើរ ទ្រង់ញុំាងធម្មចក្រ ឲ្យប្រព្រឹត្តទៅ ការត្រាស់ដឹងលើកទី ១ មានពួកសត្វ ចំនួនមួយសែនកោដិ ។

អបរំបិ ឆម្ំ នេសេន្តេ កណាសេជ្ជេ ឧរុត្តមេ

ឧរុតិគោជិសមាសញ្ជនំ ទុតិយោភិសមយោ អហុ។

យមកប្បាដិហារិយំ ឧស្សយេ្ត សនេវាគេ

អសីតិគោជិសមាសញ្ជនំ តតិយោភិសមយោ អហុ។

សន្និចាតា តយោ អាសុំ សិទ្ធិសញ្ជាបិ មហេសិនោ

ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។

កិក្កុសតសមាសញ្ជនំ បឋមោ អាសិ សមាគមោ

អសីតិភិក្ខុសមាសញ្ជនំ ទុតិយោ អាសិ សមាគមោ។

សត្តតិភិក្ខុសមាសញ្ជនំ តតិយោ អាសិ សមាគមោ

អនុបលិត្តោ បទុមវ គោយម្ហិ សម្ប្បវ្ជ្ជិតំ ។

អហាន្តេន សមយេន អរិន្ទមោ នាម ខត្តិយោ

សម្ពុទ្ធប្បមុខំ សង្ឃំ អន្នបានេន តប្បយិ ។

កាលព្រះសិខី ប្រសើរជាងគណៈ ទុត្តមជាងជន ទ្រង់សម្តែងធម៌ដទៃទៀត ការត្រាស់ដឹងលើកទី ២ មានពួកសត្វចំនួន ៩០ ពាន់កោដិ ។ កាលព្រះសិខី ទ្រង់សម្តែងយមកបាដិហារ្យក្នុងមនុស្សលោក ព្រមទាំងទេវលោក ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៨០ ពាន់កោដិ ។ ព្រះមហេសីព្រះនាមសិខី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាពួកព្រះខីណាស្រពតគមានមន្ទិល មានចិត្តស្ងប់រម្ងាប់ ប្រកបដោយគាទិគុណ ។ សន្និបាតលើកទី ១ មានភិក្ខុចំនួនមួយសែនរូប សន្និបាតលើកទី ២ មានពួកភិក្ខុចំនួន ៨ ហ្មឺនរូប ។ សន្និបាតលើកទី ៣ មានពួកភិក្ខុចំនួន ៧ ហ្មឺនរូប ជាសមាគមមិនប្រឡាក់ (ដោយពួកប៉ុប៉ុផ្ងន) ដូចបទុមជាតដែលលូតលាស់នៅក្នុងទឹក ។ សម័យនោះ តថាគតជាក្សត្រ នាមអនុម: បានញ៉ាំងព្រះសង្ឃ មានព្រះសម្ពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ។

វិសាខមហោ សិរីពុទ្ធវំសោ

ពហុទុស្សវរំ ធត្វា　　ទុស្សកោដឹ អនប្បកំ

អលង្កតំ ហត្ថិយានំ　　សម្ពុទ្ធស្ស អធាសហំ ។

ហត្ថិយានំ ឯម្ហិ ឯត្វា　　កប្បិយំ ឧបធាមយឺ

ឃ្លាយឺ មានសំ មយ្ហំ　　ឯទ្ធំ ឧឡ្ហមុបដ្ឋិតំ ។

សោឯមំ ពុទ្ធោ ព្យាកាសិ　　សិខី លោកក្ខជាយកោ

ឯកគ្គឺសេ ឥតោ កប្បេ　　អយំ ពុទ្ធោ ភវិស្សតិ ។

អហុ កបិលវ្ហយា រម្មា　　ឯក្ខមិត្វា តថាគតោ

បធានំ បធហិត្វាន　　កត្វា ទុក្ករការកំ ។

អជបាលរុក្ខមូលស្មឺ　　ឯសីនិត្វា តថាគតោ

តត្ថ ចាយាសំ បក្ខយ្ហ　　នេរញ្ជរមុបេហិតំ ។

